CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៣ ថ្ងៃទី០១-៣១ ខែកក្កដា ឆ្នាំ២០១០ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ៣៩

## មាតិកា



**អ្នកបរិស្ថានស្នើឱ្យយុវជនគិតគូរអំពីបញ្ហាអាកាសធាតុ** ទំព័រ ៥



**ការីតាសប្រារព្ធខួប ២០ឆ្នាំ ក្នុងការបម្រើប្រជាជនខ្មែរ** ទំព័រ ៩



**ទោសសម្រាប់វិន័យព្រះសង្ឃ** ទំព័រ ១៧

# ឯកអគ្គរាជទូតសម្តេចប៉ាប បញ្ចប់បេសកកម្មការទូតនៅកម្ពុជា



លោកសាលវ៉ាទ័រ ពេណ្ណាស៊ីអូ ឯកអគ្គរាជទូតសម្តេចប៉ាបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ បញ្ចប់បេសកកម្មការទូតរបស់ខ្លួន បន្ទាប់ពីសម្តេចប៉ាបបេណេឌីកទី១៦ បានតែងតាំងរូបលោកធ្វើជាឯកអគ្គរាជទូតរបស់បុរីវ៉ាទីកង់ ប្រចាំនៅប្រទេសឥណ្ឌាកាលពីថ្ងៃទី៨ ខែឧសភាកន្លងទៅ។ ទំព័រទី១០_១១




កម្មវិធីវិទ្យុ

**អេម៉ាន្ញូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : **FM 102.5 Mhz** ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : **FM 91.0 Mhz** ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប : **FM 102.5 Mhz** ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : **FM 88.5 Mhz** ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : **FM 100.5 Mhz** ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : **FM 107.5 Mhz** ម៉ោង៥:០០-៦:០០ រសៀលថ្ងៃសៅរ៍
កំពត : **FM 93.25 Mhz** ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

July-2010.qxd 7/6/2010 8:59 AM Page 2

# រូបថតប្រចាំខែ


Photo : S. Philong


Photo : S. Philong

ការជិះទោចក្រយានយន្តមិនប្រុងប្រយ័ត្ន និងប្រមាទ ដោយមិនពាក់មួយសុវត្ថិភាព និងដឹកមនុស្សលើសចំណុះ គឺជាការល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា។ មិនត្រឹមតែប៉ុណ្ណោះទង្វើនេះនឹងបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់ខ្លួនឯងនៅថ្ងៃណាមួយ និងផ្ដល់ទុក្ខដល់គ្រួសារផងដែរ។

ការនិយាយទូរស័ព្ទនៅពេលកំពុងមានភ្លៀងធ្លាក់ប្រឈមមុខនឹងគ្រោះថ្នាក់វន្ទះបាញ់។ ដូច្នេះប្រជាជនគួរគប្បីយកចិត្តទុកដាក់ចំពោះបញ្ហានេះ។


Photo : L. Sovanna

ពិធីបង្ហោះគោមដែលជាប្រពៃណីរបស់អ្នកភូមិចំការទៀង ឃុំគួស ស្រុកត្រាំកក់ ខេត្តតាកែវនៅពេលបុណ្យសំខាន់ៗ **(ឆ្វេង)**

នេះជាការចុះបញ្ជីដីធ្លីនៅភូមិកកោះ ឃុំសំពង់ជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម **(ស្ដាំ)**


Photo : L. Sovanna


Photo : L. Sovanna


Photo : S. Philong

ការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធមានសារៈសំខាន់បំផុតសម្រាប់ប្រជាពលរដ្ឋបានទទួលដីយកទៅប្រើប្រាស់ជាកម្មសិទ្ធិ ដោយមិនមានការព្រួយបារម្ភ តាមតម្រូវការផ្សេងៗដូចជាធ្វើកសិកម្មចិញ្ចឹមជីវិតប្រចាំថ្ងៃ។

ដាក់លូនៅចំហនៅពេលជួសជុលដោយមិនដាក់សញ្ញាសម្គាល់នឹងបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់អ្នកដំណើរ

# វិចារណកថា

## ទាំងអស់គ្នាចូលរួមការពារបរិស្ថានសម្រាប់អ្នកជំនាន់ក្រោយ



លោកលី សុវណ្ណា ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)

**ប្រិយមិត្តអ្នកអានជាទីមេត្រី !**

អ្នកនាំលេខនេះ សូមនាំបងប្អូនឱ្យចាប់អារម្មណ៍ចំពោះការការពារបរិស្ថាន ។ ភាពស្អាតជាសិល្បៈមួយដ៏ប្រសើរ សម្រាប់ការរស់នៅរបស់មនុស្សគ្រប់រូបនិងនាំឱ្យមនុស្សរស់នៅប្រកបដោយសុខុមាលភាព ។ ការបំផ្លាញបរិយាកាសនៅកន្លែងខ្លួនគឺជាការសម្លាប់ខ្លួនឯង ។

បើតាមជំនឿរបស់គ្រីស្តសាសនា យើងជឿថាព្រះជាម្ចាស់បានបង្កើតអ្វីៗគ្រប់យ៉ាង រួមទាំងបរិយាកាសផង ដើម្បីបម្រើប្រយោជន៍ដល់មនុស្ស ។ ដូច្នេះមនុស្សត្រូវ ថែរក្សាឱ្យបានល្អប្រពៃ សម្រាប់ការរស់នៅរបស់ខ្លួននៅពេលបច្ចុប្បន្ន ក៏ដូចជា តទៅអនាគត ។ តើយើងត្រូវរួមគ្នាការពារបរិស្ថានដោយរបៀបយ៉ាងណា ?

ជួនកាលយើងម្នាក់ៗគិតរឿងធំៗជាមុន ។ ប៉ុន្តែភ្លេចរឿងតូចតាច ដែលនៅជុំវិញការរស់នៅប្រចាំថ្ងៃរបស់ខ្លួនដែលខ្លួនអាចធ្វើបាន ។ ពេលមានសំណួរអំពីបរិស្ថាន អ្នកខ្លះឆ្លើយភ្លាមថា នេះជារឿងរបស់រាជរដ្ឋាភិបាលដែលត្រូវធ្វើ ។ ជាការពិត! នេះគឺជាតួនាទីរដ្ឋាភិបាលជាអ្នកធ្វើ ។ ប៉ុន្តែយើងទាំងអស់គ្នាក៏ត្រូវចូលរួមផងដែរ ទើបអាចសម្រេចផល ។

ការវេចខ្ចប់សំរាម និងញែកទៅតាមប្រភេទរបស់វាដោយត្រឹមត្រូវ គឺជាការចូលមួយដ៏ប្រសើរ ក្នុងការការពារបរិស្ថាន និងនាំឱ្យបរិយាកាសបរិសុទ្ធ ។ ការប្រែប្រួលអាកាសធាតុគឺជាកង្វល់យ៉ាងធំសម្រាប់ពិភពលោក ។

សូមបងប្អូនសួរខ្លួនឯងថា តើការវេចខ្ចប់សំរាមរបស់បងប្អូនបានត្រូវដែរឬទេ ? តើខ្ញុំបោះសំរាមតាមធុងត្រឹមត្រូវឬទេនៅទីសាធារណៈ ? តើថង់ផ្លាស្ទិកដែលបងប្អូនប្រើ ហើយបោះចោលនៅកន្លែងណា ? ការកាត់បន្ថយប្រើថង់ផ្លាស់ស្ទិក ក៏ជាការចូលរួមការពារបរិស្ថានផងដែរ ព្រោះវត្ថុនេះមិនងាយនឹងរលាយក្នុងដីឡើយ ។ សូមយើងចូលរួមទាំងអស់ រួមគ្នា ដើម្បីការពារទ្វីបភូមិឋានឱ្យបានស្អាតបរិយាកាសល្អ និងការរស់នៅប្រកបដោយផាសុខភាព ដែលនាំឱ្យសង្គមរីកចម្រើន ។




**ការិយាល័យព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

អ្នកសម្របសម្រួល : លោកស៊្រីប្រាម៉ុង វីរៈជ័យ ។ ប្រធាន : លោកលី សុវណ្ណា ។

Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

## កម្មវិធីវិទ្យុព្រះសហគមន៍កាតូលិក

### អ្នកចូលរួមកម្មវិធីអេម៉ាន្ញូអែល "សម្លេងពីព្រះសហគមន៍កាតូលិក" ខែកក្កដា

-ថ្ងៃអាទិត្យទី០៤ ខែកក្កដា : អាទិត្យទី១៤ ក្នុងរដូវធម្មតា ចូលរួមដោយលោកបូជាចារ្យ ទម្លាប់ សុផល មកពីព្រះសហគមន៍បាត់ដំបង។

-ថ្ងៃអាទិត្យទី១១ ខែកក្កដា : អាទិត្យទី១៥ ក្នុងរដូវធម្មតា ចូលរួមដោយបងស្រី ប៉ៅឡា មកពីគ្រឹះស្ថានរបស់សម្តេចប៉ាបសម្រាប់សាសនទូតក្រៅប្រទេស (PIME)។

-ថ្ងៃអាទិត្យទី១៨ ខែកក្កដា : អាទិត្យទី១៦ ក្នុងរដូវធម្មតា ចូលរួមដោយលោកម្ចង រស់ និស្សិតទេវវិទ្យាល័យសន្ត យ៉ូហាន ម៉ារី វីយ៉ាណៃ រាជធានីភ្នំពេញ។

-ថ្ងៃអាទិត្យទី២៥ ខែកក្កដា : អាទិត្យទី១៧ ក្នុងរដូវធម្មតា ចូលរួមដោយលោកបូជាចារ្យបប់ ពិសេ មកពីក្រុមសាសនទូតក្រៅប្រទេសនៅកេបិក (SME)។

### "ខ្ញុំត្រូវការអ្នក" ខែកក្កដា (FM 99.5 Mhz ច័ន្ទ,អង្គារ ម៉ោង១០-១១ព្រឹក)

ថ្ងៃទី០៥ កក្កដា : យុវវ័យ និងលំហាត់ប្រាណ។ ថ្ងៃទី០៦ កក្កដា : បាល់ទាត់ពិភពលោក ពាក់កណ្តាលផ្តាច់ព្រ័ត្រ។ ថ្ងៃទី១២ កក្កដា : សុបិនជាតារា។ ថ្ងៃទី១៣ កក្កដា : ជប់ លៀងហ៊ឺហា ផឹកសុរាឬ? ថ្ងៃទី១៩ កក្កដា : ពឹងគេ ឬពឹងខ្លួន។ ថ្ងៃទី២០ កក្កដា : មហិច្ឆិតាយុវវ័យ។ ថ្ងៃទី២៦ កក្កដា : ឥទ្ធិពលនៃទង្វើ។ ថ្ងៃទី២៧ កក្កដា : ស្នេហាបោកបញ្ឆោត។ សូមបញ្ជាក់ថា ប្រធានបទទាំងនេះនឹងមានការចូលរួមបកស្រាយពីវាគ្មិន ដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់។

**សូមកុំភ្លេចតាមដាន!**

July-2010.qxd 7/6/2010 9:00 AM Page 4

# សេដ្ឋកិច្ច

## តម្លៃទំនិញឡើងថ្លៃប្រមាណ ៤,៥%

**ខាន់ ភីរម្យ**

"យោងទៅតាមរបាយការណ៍ ពីវិទ្យាស្ថានជាតិស្ថិតិបានឱ្យដឹងថាតម្លៃទំនិញប្រើប្រាស់ក្នុងប្រទេសកម្ពុជាកាលពីខែឧសភាកន្លងទៅនេះ មានការកើនឡើងប្រមាណជា៤,៥%"។ នេះបើយោងតាមការប្រៀបធៀបនឹងតួលេខកាលពីអំឡុងខែឧសភាឆ្នាំ២០០៩កន្លងទៅ។

វិទ្យាស្ថានជាតិស្ថិតិ បានអះអាងថា មូលហេតុនៃការកើនឡើងតម្លៃរបស់ប្រើប្រាស់នេះ គឺដោយសារតែការឡើងថ្លៃនូវតម្លៃប្រេងឥន្ធនៈ។ ប្រភពដដែលនោះបានឱ្យដឹងថា តាមតម្លៃលើទីផ្សារនៅប្រទេសកម្ពុជា តាំងតែពីខែឧសភា ឆ្នាំ២០០៩មកតម្លៃប្រេងឥន្ធនៈកើនឡើងក្នុងរង្វង់២៧.៣%។

ក្រៅពីការកើនឡើងនូវតម្លៃរបស់ប្រេងឥន្ធនៈហើយនោះ គេកត់សម្គាល់ឃើញថា មានការហើមឡើងនូវលុយរៀលផងដែរ។ យោងទៅតាមអត្រាប្តូរប្រាក់លីហួ ភ្នំពេញ ក៏បានឱ្យដឹងថា មកដល់ពាក់កណ្តាលខែមិថុនាកន្លងទៅ លុយរៀល គឺបានហើមឡើងរហូតដល់ ៤២៥៦រៀល នៅក្នុង មួយដុល្លារអាមេរិក។ វាបានហើមឡើងនៅក្នុងរង្វង់ ១,៦% បើប្រៀបធៀបកាលពីពាក់កណ្តាលខែមេសាកន្លងទៅ ដោយនៅពេលនោះ តម្លៃលុយរៀលស្ថិតនៅ



Photo : S. Philong

ក្នុងរង្វង់ត្រឹមតែ ៤១៩០រៀល ក្នុងមួយដុល្លារ។

ដោយសារតែមានការហើមឡើងនូវតម្លៃលុយរៀលជាបន្តបន្ទាប់កាលពីអំឡុងខែមិថុនាកន្លងទៅនេះ ធនាគារជាតិកម្ពុជា បានប្រកាសដេញថ្លៃលុយដុល្លារប្រមាណជា ៧លានដុល្លារ ដើម្បីធ្វើការជួយសង្គ្រោះលុយរៀលកុំឱ្យធ្លាក់ថ្លៃតទៅទៀត។

ពាក់ព័ន្ធនឹងការធ្លាក់ចុះនេះ មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានមានប្រសាសន៍ កាលពីពេលថ្មីៗនេះថា នៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី ក្រសួងមិនអាចដាក់សំពាធទៅលើលុយឱ្យមានការបញ្ចុះថ្លៃអ្វីបាននោះទេ។ ប៉ុន្តែទោះបីជាយ៉ាងណា កន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តែងផ្តល់អនុសាសន៍ជាបន្តបន្ទាប់ទៅកាន់ធនាគារ និងក្រុមហ៊ុននានា។

ក្រៅពីប្រេងឥន្ធនៈចេញ ចំពោះតម្លៃទំនិញ ឬក៏សម្ភារៈ ដែលវិទ្យាស្ថានជាតិស្ថិតិបានអះអាង មានការឡើងថ្លៃដែរ នោះមានតាំងពីតម្លៃម្ហូបអាហារ ភេសជ្ជៈ សម្លៀកបំពាក់ តម្លៃនៃសេវាកម្ម ការដឹកជញ្ជូន អគ្គិសនី ទឹក ថ្នាំជក់ គ្រឿងថែទាំសុខភាព ឬរូបរាងកាយជាដើម-ល-។

### កង្វល់ប្រជាពលរដ្ឋម្នាក់

ការបន្តឡើងថ្លៃនូវរបស់ប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគ បានធ្វើឱ្យប្រជាជនកម្ពុជាដែលមានប្រាក់ចំណូលទាបមានការព្រួយបារម្ភ។

លោកជា សាដា អ្នករត់ម៉ូតូឌុបអាយុ ៣៦ឆ្នាំបានឱ្យដឹងថា ការបន្តឡើងថ្លៃទំនិញនេះកំពុងតែផ្តល់ផលប៉ះពាល់ដល់គ្រួសារគាត់ជាពិសេស គឺការធ្លាក់ចុះនៃប្រាក់ចំណូល។ តែចំណាយបែរជាមានការកើនឡើង។ លោកបានឱ្យដឹងថា កាលពីមុន គាត់រត់ម៉ូតូឌុប ក្នុងមួយថ្ងៃបាន១៥០០០រៀល ទៅ២០០០០រៀល តែឥឡូវនេះគឺអាចបានដដែលនៅថ្ងៃខ្លះ តែការចំណាយវិញគឺអត់ដដែលទេ។ លោកបញ្ជាក់ទៀតថា: "ពីមុនគ្រួសារខ្ញុំទិញម្ហូបតែ១០០០០រៀល អាចហូបបានមួយថ្ងៃ។ ឥឡូវនេះទាល់តែ១៥០០០រៀល ទើបគ្រាន់"។

គួរបញ្ជាក់ថា លោកសាដាគឺគ្រាន់តែជាឧទាហរណ៍នៃអ្នករត់ម៉ូតូឌុបម្នាក់ ខណៈដែលនៅក្នុងប្រទេសមានអ្នករត់ម៉ូតូឌុបរាប់ពាន់នាក់។

# សុខភាព

## "ត្រូវទៅជួបនិងគ្រូពេទ្យជំនាញមុននឹងប្រើថ្នាំគ្រុនចាញ់"

**ជាត សំភី**

"មុននឹងលេបថ្នាំគ្រុនចាញ់ យើងចាំបាច់ត្រូវទៅជួបនិងគ្រូពេទ្យជំនាញ ដើម្បីធ្វើតេស្តឈាម ថាតើយើងមានគ្រុនចាញ់ដែរឬទេ?" នេះគឺជាប្រសាសន៍របស់លោកមាស ថា អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់។

លោកមាស ថា មានប្រសាសន៍សង្កត់ធ្ងន់ដែរថា ការលេបថ្នាំជំងឺគ្រុនចាញ់ត្រូវគោរពតាមលក្ខខណ្ឌរបស់លោកគ្រូពេទ្យ។ ប្រសិនបើអ្នកជំងឺលេបថ្នាំតែមួយថ្ងៃ ពីរថ្ងៃ គាត់ឃើញធូរ ហើយគាត់ឈប់លេប។ ជំងឺគ្រុនចាញ់នឹងលាប់ឡើងវិញ ពេលនោះអ្នកជំងឺនឹងមានការពិបាក និងមានគ្រោះថ្នាក់។




Photo : DR

ថ្នាំជំងឺគ្រុនចាញ់ ដែលក្រសួងសុខាភិបាលណែនាំ ឱ្យប្រើ មានអាតេស៊ុណាត **(Artesunate)** និងមេស្លូគីន**(Mesloquine)**។ ថ្នាំនេះមិនមានលក់លើទីផ្សារឡើយ។អ្នកជំងឺគ្រុនចាញ់អាចរកថ្នាំបាននៅតាមមណ្ឌលសុខភាព ឬក៏តាមអ្នកស្ម័គ្រចិត្តភូមិ។ ថ្នាំដែលមានលក់លើទីផ្សារ មានដូចជា **Malarine** ជាដើម។ ប៉ុន្តែប្រសិនអ្នកជំងឺសង្ស័យថា គាត់កើតគ្រុនចាញ់ដូចជា ឈឺ ព្រឺរងារ ឬក៏ឡើងកម្តៅ គាត់មិនត្រូវទៅទិញថ្នាំផ្សំដោយខ្លួនឯងទេ។ គាត់ត្រូវទៅឱ្យគ្រូពេទ្យជំនាញពិនិត្យ ឬចេញវេជ្ជបញ្ជាទៅទិញថ្នាំនៅឱសថស្ថានដែលមានសុវត្ថិភាព។

លោកមាស ថា ក៏មានប្រសាសន៍បន្តថា ករណីគ្រុនចាញ់នៅប្រទេសកម្ពុជានៅតែខ្ពស់ជាងគេ បើប្រៀបធៀបនឹងប្រទេសនៅក្នុងតំបន់។ ករណីអ្នកស្លាប់ដោយសារជំងឺគ្រុនចាញ់នៅតែមាន។ ទោះបីជាយ៉ាងណា រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នៅតែខិតខំឆ្លើយតបបង្ការ និងព្យាបាលជំងឺគ្រុនចាញ់នេះ។ ដូច្នេះបច្ចុប្បន្ននេះប្រជាពលរដ្ឋមានការយល់ដឹងច្រើនដោយបានផ្លាស់ប្តូរទម្លាប់ពីការគិតអបិយជំនឿ ពីការចាញ់ទឹកដី មកប្រើមុងការពារវិញ។

July-2010.qxd 7/6/2010 9:00 AM Page 5





Photo : S. Philong

# អ្នកបរិស្ថានស្នើឱ្យយុវជនគិតគូរបញ្ហាបម្រែបម្រួលអាកាសធាតុ

**ខាន់ ភីរម្យ**

ក្នុងគោលបំណងទប់ស្កាត់នូវគ្រោះថ្នាក់ផ្សេងៗបណ្តាលមកពី បម្រែបម្រួលអាកាសធាតុ លោកតឹក វណ្ណារ៉ា ជាអ្នកស្រាវជ្រាវនៅសមាគមអភិរក្សវប្បធម៌ និងបរិស្ថានកម្ពុជា(CEPA) បានស្នើសុំឱ្យយុវជន ចូលរួមសន្សំសំចៃ និងកុំធ្វើសកម្មភាពណាដែលអាចនឹងបំពុលបរិយាកាស ។

លោកវណ្ណារ៉ា មានប្រសាសន៍ថា បម្រែបម្រួលអាកាសធាតុបាន និងកំពុងតែលេចរូបរាងនៅក្នុងប្រទេសកម្ពុជា នៅក្នុងនោះមានភាពរាំងស្ងួត ទឹកជំនន់ កំណើនសីតុណ្ហភាព ការកើនឡើងនូវកម្រិតទឹកសមុទ្រ និងខ្យល់ព្យុះជាដើម ។ ដូច្នេះការចូលរួមរបស់យុវជនដែលជាទំពាំងស្នងឫស្សី មានសារៈសំខាន់ណាស់ចំពោះសង្គមនិងបរិស្ថានរបស់មនុស្សទូទៅនៅលើលោកនេះ ។

លោកក៏បានឱ្យដឹងថា យុវជនកម្ពុជាម្នាក់អាចចូលរួមកាត់បន្ថយផលប៉ះពាល់មកពីបម្រែបម្រួលអាកាសធាតុនេះទៅតាមគ្រប់រូបភាពទាំងអស់នៅក្នុងជីវភាពប្រចាំថ្ងៃ ។ លោកបញ្ជាក់ដែរថាយុវជនម្នាក់ៗអាចចូលរួមបានតាមរយៈការសន្សំនូវថាមពល ការភ្ញាក់រលឹកលើការគ្រប់គ្រងកាកសំណល់ និងការសន្សំសំចៃលើការប្រើប្រាស់របស់ផ្សេងៗពីព្រោះផលិតកម្មរបស់វត្ថុប្រើប្រាស់ គឺសុទ្ធតែមានផលប៉ះពាល់ទៅលើបរិស្ថានទាំងអស់ គ្រាន់តែតិចនិងច្រើនតែប៉ុណ្ណោះ ។

លោកក៏បានឱ្យដឹងថា ឧទាហរណ៍គាត់អាចចូលរួមសន្សំសំចៃថាមពល ។ ពេលសិក្សា គួរសិក្សារួមគ្នា ។ បើធ្វើដំណើរទៀត គប្បីប្រើប្រាស់យានជំនិះរួមគ្នា ។ ពួកគាត់គួរគ្រប់គ្រងកាកសំណល់ផ្សេងៗពីព្រោះពួកវាអាចនឹងធ្វើឱ្យមានបរិយាកាសបំពុលអាប់អួរ ហើយមានបញ្ហាលើធនធានទឹកផងដែរ ។

លោកបានបញ្ជាក់ថា: "បើពួកគាត់អាចធ្វើបានមែន មានន័យថា គាត់ជួយសន្សំសំចៃការចំណាយខ្លួនឯងផង និងជួយទប់ស្កាត់ការបំពុលបរិយាកាសបានមួយភាគដែរ" ។

ឈាង យ៉ាដា យុវនិស្សិតមហាវិទ្យាល័យគ្រប់គ្រងឆ្នាំទី២ បានឱ្យដឹងថា មកដល់ពេលនេះ រូបគេកំពុងអនុវត្តទង្វើមួយចំនួនដែលធ្វើឱ្យរូបគាត់អាចកាត់បន្ថយការចំណាយបានមួយចំនួន ហើយក៏អាចចូលរួមទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិយាកាសដែលនាំឱ្យកើតមាននូវបម្រែបម្រួលអាកាសធាតុបានមួយផ្នែកផងដែរ ។ លោកបានបញ្ជាក់ថា: "ពីមុន ខ្ញុំអត់ចេះគេងងងឹតទេ ។ បើចង់គេងលក់ គឺយ៉ាងហោចណាស់ ក៏បើកអំពូលពងមាន់មួយដែរ ។ ប៉ុន្តែពេលនេះ ខ្ញុំអាចគេងងងឹតបាន" ។

ជា សំណាង យុវជនអាយុ១៩ឆ្នាំ នៅវិទ្យាល័យឫស្សីកែវ បានឱ្យដឹងដែរថាពីមុនរូបគេមិនសូវចាប់អារម្មណ៍នឹងការបម្រែបម្រួលអាកាសធាតុឡើយ ។ ក្រោយមក ប៉ាម៉ាក់ ជាអ្នកដែលជំរុញឱ្យរូបគេចូលរួមសន្សំសំចៃសម្រាប់គ្រួសារ និងបរិស្ថាន ។

សំណាងមានអាណាព្យាបាលធ្វើជាមន្ត្រីរាជការតែងតែណែនាំរូបគេឱ្យមានការយល់ដឹងអំពីបម្រែបម្រួល អាកាសធាតុ និងមានគំនិតសន្សំសំចៃនេះឡើង ។ សំណាងបានបញ្ជាក់ដែរថា: "ប៉ាគាត់ធ្លាប់ប្រាប់ខ្ញុំថា ជិះម៉ូតូខ្លួនឯងមួយអាទិត្យ ហោចណាស់ខ្ញុំត្រូវចំណាយលុយចាក់សាំង ៣លីត្រ និងបញ្ចេញផ្សែងច្រើន ។ ប៉ុន្តែប្រសិនគាត់ជូនទៅ សាំងក៏អត់អស់ ហើយក៏បន្ថយផ្សែងបំពុលដែរ" ។

ជុំវិញបញ្ហាទាំងអស់នេះ លោក វណ្ណារ៉ា បានឱ្យដឹងថា មកដល់ពេលនេះ កម្ពុជាមានលទ្ធភាពបន្សាំនឹងបម្រែបម្រួលអាកាសធាតុនេះតិចតួចណាស់ ។ ដូច្នេះយុវជនទាំងអស់ក៏គួរតែចូលរួមទប់ស្កាត់ការបំពុលបរិយាកាសនេះ ។

July-2010.qxd 7/6/2010 9:00 AM Page 6

## កសិកម្ម

# សួនដំណាំជួយឱ្យចំណេញសេដ្ឋកិច្ចគ្រួសារ

**ជាត សំភី**


Photo : P. Samphy

លោកអ៊ី ណារ៉ុន មន្ត្រីគ្រប់គ្រងគម្រោងនៃមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ហៅកាត់ថា សេដាក មានប្រសាសន៍ឱ្យដឹងថា៖

សួនដំណាំជាលក្ខណៈគ្រួសារជាសួនមួយ ដែលកសិករអាចរៀបចំបាននៅទីធ្លាជុំវិញផ្ទះ ឬក៏កន្លែងដែលគាត់គិតថា នៅសល់ដីល្មមអាចរៀបចំបាន។ ហើយដំណាំដែលយកមកដាំមិនចាំបាច់ច្រើនក៏បាន ជាពិសេស ដំណាំដែលទាក់ទងនឹងការបរិភោគជាប្រចាំថ្ងៃ ដូចជា ម្ទេស ខ្ទឹម ជី ឬស្លឹកគ្រៃជាដើម។

សួនដំណាំជាលក្ខណៈគ្រួសារ មានអត្ថន័យ និងផលប្រយោជន៍ខ្ពស់ណាស់ ពីព្រោះប្រសិន កសិកររៀបចំធ្វើ គាត់ក៏អាចមានបន្លែហូបរាល់ថ្ងៃ ដូចជាស្លឹកគ្រៃ ជី ខ្ទឹម បន្លែផ្សេងៗ... ដែលអាហារទាំងនេះផ្តល់វិតាមីននិងប្រូតេអ៊ីន ដែលចាំបាច់សម្រាប់សុខភាព។ ម្យ៉ាងបន្លែដែលគាត់ដាំខ្លួនឯង ជាបន្លែធម្មជាតិ មិនប្រើជាតិគីមី ដែលអាចធ្វើឱ្យប៉ះពាល់ដល់សុខភាពផង។

ទោះបីជាយ៉ាងណា បើតាមបទពិសោធន៍របស់លោកអ៊ី ណារ៉ុន កន្លងមក កសិករមិនសូវបានចាប់អារម្មណ៍ធ្វើសួនដំណាំទេ ដោយសារហេតុផល ជាច្រើន។ ទី១ គាត់គិតថា គ្រឿងទេស ដូចជា ម្ទេស ឬខ្ទឹម មិនចាំបាច់ដាំក៏បាន ពីព្រោះគាត់អាចទិញគេ ១០០រៀល ២០០រៀល ឬសុំគេក៏បាន។ ប៉ុន្តែគាត់មិនបានវិភាគថា បើគាត់មានបន្លែខ្លួនឯងគាត់អាចសន្សំ ១០០រៀល ឬ២០០រៀល ក្នុងមួយថ្ងៃ។ ក្នុងមួយឆ្នាំ ៥ឆ្នាំ ឬ១០ឆ្នាំ គាត់គឺអាចសល់លុយ ច្រើនណាស់។ ទីពីរ នៅពេលដាំបន្លែ គាត់គិតថា ខ្វះខាតទឹក។ តាមពិតបន្លែបន្តិចបន្តួចមិនត្រូវការទឹកច្រើនទេ គាត់អាចដួសទឹកពាងស្រោចក៏បាន។ ទីបី គាត់ខ្វះព័ត៌មានអំពីការផ្សព្វផ្សាយអំពីការធ្វើសួនហ្នឹង ទើបគាត់មិនសូវចាប់អារម្មណ៍។

លោកអ៊ី ណារ៉ុន ផ្តល់យោបល់ថា កសិករគួរតែរៀបចំសួនដំណាំជាមួយនិងផែនការច្បាស់លាស់ថាគួរដាំអ្វី? និងដាំនៅពេលណា? ហើយដំណាំអ្វីខ្លះដែលគ្រួសារគាត់ត្រូវការជាងគេ ?

កសិករអាចធ្វើការបែងចែកប្រភេទដំណាំដែលត្រូវដាំ។ ដំណាំខ្លះមិនត្រូវការរដូវទេ។កសិករអាចដាំពេលណាក៏បាន ដូចជាពពួកខ្ទឹម ស្លឹកគ្រៃ ជី...។ ប៉ុន្តែដំណាំខ្លះមានរដូវដូចជា សាលាដ ស្ពៃ... ដាំខែក្តៅមិនសូវល្អទេ។ គេដាំបានតែនៅក្នុងខែត្រជាក់ទើបបានហុចផលល្អ។ ចំនុចដែលសំខាន់មួយទៀតនោះ នៅពេលកសិករធ្វើសួនដំណាំ គាត់គួរធ្វើរបងព័ទ្ធឱ្យបានល្អ ដើម្បីកុំឱ្យសត្វចូលមកបំផ្លាញ ដែលធ្វើឱ្យគាត់អស់ទឹកចិត្តក្នុងការដាំ។

## បរិស្ថាន

# អង្គការការពារទន្លេបីបារម្ភអំពីគុណភាពទឹកតាមដងទន្លេភាគឦសាន

លោកមៀច មាន អ្នកសម្របសម្រួលអង្គការបណ្តាញការពារទន្លេសេសាន សេកុង និងស្រែពក ដែលជាទន្លេបីហូរកាត់បណ្តាខេត្តភូមិភាគឦសាននៃប្រទេសកម្ពុជា បានសម្តែងការព្រួយបារម្ភអំពីការធ្លាក់ចុះគុណភាពទឹកតាមដងទន្លេទាំងនេះ។

លោកក៏បានឱ្យដឹងថា នៅក្នុងរដូវប្រាំងឆ្នាំនេះ កម្រិតទឹកនៅតាមដងទន្លេទាំងបីគឺមានការប្រែប្រួលយ៉ាងខ្លាំង ជាពិសេសទន្លេសេសាន។ លោកបានបញ្ជាក់ថា៖ "គ្រាន់តែទន្លេសេសានមួយ នាឆ្នាំនេះទឹករីងឡើងចង់ស្ងួតដល់ទៅបីដង"។ ទាក់ទងនឹងការប្រែប្រួលនៃទឹករបស់ទន្លេទាំងនេះ លោកបានអះអាងថា វាអាចផ្តល់នូវផលប៉ះពាល់យ៉ាងច្រើនដូចជាការប្រែប្រួលនៃគុណភាពទឹក បាត់បង់ជីវសាស្ត្រចម្រុះ បាត់បង់ត្រី និងប្រែប្រួលកម្រិតជីវភាពរបស់ប្រជាពលរដ្ឋតាមដងទន្លេ។ លោកក៏បានបន្តទៀតថា ក្នុងចំណោមផលប៉ះពាល់ទាំងនេះ គុណភាពទឹក ជាសេចក្តីកង្វល់ចម្បងមួយពីព្រោះក្រោយពេលដែលទឹករីង បានធ្វើឱ្យងាប់ជីវចម្រុះដែលមាននៅក្នុងទន្លេ។ ហើយនៅពេលដែលទឹកមានឡើងវិញ ធ្វើឱ្យទឹកនោះមានក្លិនស្អុយ។

ក្រៅពីទន្លេទាំងបីនេះ កម្រិតទឹកនៅតាមដងទន្លេមេគង្គ ដែលជាប្រភពទឹកមួយ ដ៏សំខាន់របស់ប្រទេសកម្ពុជាក៏មានការធ្លាក់ចុះផងដែរ។ ចំពោះការធ្លាក់ចុះនេះបានត្រូវលើកឡើងដោយគណៈ-កម្មាធិការទន្លេមេគង្គ កាលពីខែមេសា។

**ខាន់ ភីរម្យ**


Photo : P. Samphy

July-2010.qxd 7/6/2010 9:00 AM Page 7



# យុវជនមានឱកាសសិក្សាជំនាញនៅមជ្ឈមណ្ឌលកូមីសូ

**អ៊ឹម សុខន**



Photo : Ton

យុវនារីកំពុងតែរៀនកាត់ដេរនៅមជ្ឈមណ្ឌលកូមីសូក្រោមការគ្រប់គ្រងរបស់អង្គការដែលឧបត្ថម្ភដោយសាសនទូតកូរ៉េ

មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈកូមីសូ ស្ថិតនៅក្រោមការគ្រប់គ្រង ពីអង្គការក្រៅរដ្ឋាភិបាលនៃក្រុមសាសនទូតកូរ៉េមួយ ។ អង្គការនេះបានចាប់កំណើតថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៨ នៅកម្ពុជា ។

យោងតាមប្រសាសន៍លោកដោក វីរៈ ប្រធានចាត់ការទូទៅនៃមជ្ឈមណ្ឌល បានឱ្យដឹងថា ប្រជាជនដែលបានប្ដូរទីលំនៅពីម្ដុំប៊ូឌីញ និងម្ដុំបឹងកក់២ ភាគច្រើនគឺបានមករស់ក្នុងភូមិអណ្ដូង ភូមិត្រពាំងស្វាយ និងភូមិសែនសុខនេះ ។ អ្នកទាំងនេះ គឺមានជីវភាពខ្សត់ខ្សោយ និងរៀនសូត្របានទាប ។

ដូច្នេះអង្គការក៏បានផ្ដល់ការសិក្សាវគ្គជំនាញខ្លីជាអាទិភាពសម្រាប់អ្នកដែលមានអាយុពី១៧ឆ្នាំឡើង និងមានចំណូលតិចជាង ២ដុល្លារក្នុង ១ថ្ងៃ ។

មជ្ឈមណ្ឌលកូមីសូមានបណ្ដុះបណ្ដាលជំនាញដូចជា កាត់ដេរសម្លៀកបំពាក់បុរសនារី ដែលរៀនរយៈពេល ៣ខែកន្លះ ។ ជំនាញជាងកាត់សក់បុរស និងជួសជុលម៉ូតូរៀនរយៈពេល៣ខែ ។ ជំនាញកាត់សក់ស្ត្រី និងផាត់មុខ រៀនរយៈពេល ៦ខែ ។ ចំពោះជំនាញនីមួយ មជ្ឈមណ្ឌលកូមីសូអាចទទួលសិស្សត្រឹមតែ ១០នាក់ប៉ុណ្ណោះ ។

ក្រៅពីការផ្ដល់ជំនាញខាងលើ អង្គការមានវគ្គបណ្ដុះបណ្ដាលភាសាបរទេស និងជាតិដល់សិស្ស ។ ហើយវគ្គដែល សំខាន់ដែរនោះ គឺការវាយតម្លៃលើឥរិយាបថរបស់សិស្សតាមផ្នែក ។ លោកដោក វីរៈ ក៏មានប្រសាសន៍សង្កត់ធ្ងន់ថា បើសិស្សរៀនបានទូវជំនាញប្រាកដ ប៉ុន្តែពួកគេគ្មានសីលធមិ សុជីវធមិ និងទំនាក់ទំនងល្អនោះ ក៏មិនល្អដែរ ។

នៅពេលសព្វថ្ងៃនេះ ការលំបាកបំផុតសម្រាប់មជ្ឈមណ្ឌលកូមីសូគឺពិបាកទំនាក់ទំនងសិស្សឱ្យមកចូលរៀន ពីព្រោះឪពុកម្ដាយសិស្សតម្រូវឱ្យកូនដើរស៊ីឈ្នួលគេ ឬធ្វើការនៅតាមការដ្ឋានសំណង់ដែលនៅឆ្ងាយពីលំនៅដ្ឋាន ។ ពួកគាត់ធ្វើដូច្នេះ បន្ទាប់ពីពួកគាត់បាត់បង់នូវការងារប្រចាំថ្ងៃដោយសារតែការផ្លាស់ប្ដូរទីលំនៅ ។ ដូច្នេះពួកគាត់គិតអំពីបញ្ហាក្រពះ និងជីវភាពជាសំខាន់ភ្លាមៗ ។

សព្វថ្ងៃកូមីសូ មានសិស្សចំនួន ៤០នាក់ ដែលកំពុងសិក្សា ហើយ ៧២នាក់ បានបញ្ចប់ការសិក្សារួចហើយ ។ ចំពោះសិស្សដែលបានបញ្ចប់ការសិក្សា កូមីសូមានផ្ដល់ជាកញ្ចប់ថវិកាកម្ចីតាមតម្រូវការរបស់ពួកគេដើម្បីយកទៅប្រកបមុខរបរ ។

# "ជំនាញពិតប្រាកដ ផ្ដល់អនាគតល្អដល់ខ្ញុំ និងគ្រួសារ"

"ខ្ញុំជាក្មេងកំព្រាឪពុកម្ដាយ និងមានបងប្អូន១០នាក់ ។ យើងមិនមានអ្វីបរិភោគគ្រប់គ្រាន់ ហើយតែងតែជួបការលំបាក ជាប្រចាំថ្ងៃ" ។ នេះបើតាមសម្ដីរបស់កញ្ញាឈ្មុំ ស្រីទូចអាយុ១៧ឆ្នាំ កំពុងរៀនជំនាញផាត់មុខ និងអ៊ុតសក់ នៅអង្គការកូមីសូ ។

កញ្ញា បាននិយាយទៀតថា : "ខ្ញុំស្គាល់អង្គការនេះតាមរយៈមិត្តរបស់ខ្ញុំ ដែលគាត់បានចូលសិក្សា និងការចុះសួររបស់អង្គការនៅភូមិខ្ញុំ" ។

ដោយសារកត្តាជីវភាព និងជីវិត ជាក្មេងកំព្រាបានរុញច្រានឱ្យស្រីទូចបោះបង់ចោលការសិក្សាត្រឹមថ្នាក់ទី៦ ត្បិតក្រុមគ្រួសារ មិនមានថវិកាគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ការសិក្សារបស់កញ្ញា ។

ស្រីទូចបញ្ជាក់ថា បងប្អូននាង ស្រី ទាំង ៦នាក់មិនទាន់មានគ្រួសារទេ ។ ម្នាក់ធ្វើការរោងចក្របានប្រាក់ត្រឹម ៥០ដុល្លារ ក្នុងមួយខែៗ ។ បីនាក់ទៀតត្រូវរកចំណូលសម្រាប់គ្រួសារ ដោយក្នុងមួយថ្ងៃៗ រកបានត្រឹម ៥០០០រៀល ឬ១០០០០រៀល ដោយធ្វើជាកម្មករសំណង់ និងលើកទំនិញឱ្យគេ ។



Photo : Ton

ស្រីទូច ពោលពីទឹកចិត្តខ្លួន ដែលបានមកសិក្សាទីនេះថា : "ខ្ញុំពិតជាមានសេចក្ដីសប្បាយរីករាយណាស់ដែលបានទទួលការសិក្សាជំនាញនៅទីនេះ ។ ខ្ញុំសង្ឃឹមថា នៅពេលដែលខ្ញុំមានជំនាញពិតប្រាកដហើយនោះ ខ្ញុំនឹងជួយក្រុមគ្រួសារខ្ញុំឱ្យមានជីវភាពសមរម្យ ដូចជាគេឯង ដោយមិនខ្វះល្ងាច ខ្វះព្រឹកឡើយ ។ តទៅថ្ងៃអនាគត ខ្ញុំចង់បើកហាងអ៊ុតសក់ និងផាត់មុខមួយឱ្យសមរម្យ" ។ ស្រីទូចបន្តទៀតថា ការសិក្សានៅមជ្ឈមណ្ឌលកូមីសូមិនត្រឹមតែជួយឱ្យកញ្ញាមានជំនាញពិតប្រាកដប៉ុណ្ណោះនោះទេ ។ ប៉ុន្តែវាក៏បានធ្វើឱ្យកញ្ញាយល់ដឹងអំពីសីលធមិក្នុងការរស់នៅក្នុងសង្គម ព្រមទាំងមានសេចក្ដីសង្ឃឹមចំពោះខ្លួនឯងផងដែរ ។

July-2010.qxd 7/6/2010 9:00 AM Page 8





Photos : DR

**ខាន់ ភិរម្យ**

### រន្ទះនៅតែបន្តសម្លាប់ជីវិតពលរដ្ឋកម្ពុជា

"បាតុភូតរន្ទះបាញ់នៅតែបន្តគំរាមកំហែងជីវិតប្រជាពលរដ្ឋកម្ពុជាជាបន្តបន្ទាប់"។ នេះបើតាមការអះអាងរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

មកដល់ដើមខែមិថុនាកន្លងទៅនេះ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានឱ្យដឹងថា មានប្រជាពលរដ្ឋប្រមាណជា ៥០នាក់ បានស្លាប់ដោយសាររន្ទះបាញ់។

ជុំវិញបញ្ហាបាតុភូតរន្ទះនេះ មន្ត្រីភាគច្រើនបានស្តីបន្ទោសទៅលើការបម្រែបម្រួលអាកាសធាតុ ដែលមកដល់ពេលនេះ កម្ពុជាជាប្រទេសមួយដែលមានលទ្ធភាពបន្សាំទាបបំផុត។

ចំនួនប្រជាពលរដ្ឋកម្ពុជា ដែលបានរងគ្រោះថ្នាក់ដល់ជីវិត ដោយសារតែបាតុភូតរន្ទះនេះ បានកើនឡើងជាបន្តបន្ទាប់តាំងពីឆ្នាំ២០០៨មក។

តួលេខបានបង្ហាញផងដែរថា នៅឆ្នាំ២០០៨ ចំនួនជនរងគ្រោះមានត្រឹមតែ ៩៥នាក់ទេ។ ប៉ុន្តែនៅក្នុងឆ្នាំ២០០៩ ចំនួននេះ បានកើនឡើងរហូតដល់ទៅ ១៤០នាក់។

### កម្ពុជាបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ដែលមានសមាសភាពចំនួន ១១នាក់ ត្រូវជ្រើសតាំងកាលពីពាក់កណ្តាល ខែមិថុនា កន្លងទៅនេះ។ សមាជិកក្រុមនៃក្រុមប្រឹក្សា មានមកពីស្ថាប័នខុសៗ គ្នា។ ម្នាក់ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ។ សមាសភាពឯទៀតមកពីស្ថាប័នផ្សេងៗ ដូចជាព្រឹទ្ធសភា រដ្ឋសភា ប្រធានអង្គភាពប្រឆាំងអំពើពុករលួយនៃរាជរដ្ឋាភិបាល តំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាជ្ញាធរសវនកម្មជាតិ ក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ តំណាងរាជរដ្ឋាភិបាល និងក្រុមប្រឹក្សាអ្នកច្បាប់។ លោកតុប សម តំណាងរដ្ឋសភា ត្រូវបានបោះឆ្នោតជាប្រធាន និងលោកប្រាក់ សុខ មកពីព្រឹទ្ធសភា ជាអនុប្រធាននៃក្រុមប្រឹក្សានេះ។

### កម្ពុជានឹងបង្កើតមជ្ឈមណ្ឌលជាតិមជ្ឈត្តករពាណិជ្ជកម្ម

"មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តករផ្នែកពាណិជ្ជកម្មនឹងត្រូវបង្កើតឡើងនៅក្នុងប្រទេសកម្ពុជានៅពេលខាងមុខនេះ" ឯកឧត្តមចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានមានប្រសាសន៍ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលបេក្ខជនចំនួន ៥៤នាក់ ដែលត្រូវជ្រើសរើសឱ្យក្លាយជាក្រុមមជ្ឈត្តករដំបូងគេនៅកម្ពុជា។ ឯកឧត្តមបញ្ជាក់ថា នេះគឺជាការប្តេជ្ញាចិត្តមួយរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីកែលម្អបរិយាកាសវិនិយោគ និងបង្កើតភាពប្រកួតប្រជែងលើឆាកអន្តរជាតិ។ មជ្ឈមណ្ឌលនេះនឹងអភិវឌ្ឍកម្ពុជាឱ្យក្លាយទៅជាកន្លែងមួយដែលមានភាពទាក់ទាញសម្រាប់ការវិនិយោគ និងការធ្វើអាជីវកម្ម។ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តករផ្នែកពាណិជ្ជកម្ម គឺជាយន្តការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។ អាជីវករអាចដោះស្រាយវិវាទឆាប់រហ័ស និងចំណាយតិច ព្រមទាំងបង្កើនទំនុកចិត្តនៅក្នុងប្រព័ន្ធពាណិជ្ជកម្មកម្ពុជា។

## ទុរគតជននៅអាមេរិកធ្លាក់ចុះ តែគ្រួសារទុរគតជនកើនឡើង

បណ្តាញព័ត៌មានអេភីបានអះអាងថា វិបត្តិសេដ្ឋកិច្ចកន្លងទៅនៅតែបន្តគំរាមកំហែងដល់សេដ្ឋកិច្ចរបស់ពលរដ្ឋអាមេរិក។

ប្រភពដដែលនេះ ក៏បានឱ្យដឹងថា ចំនួនទុរគតជនអាមេរិកមានការថយចុះ។ ប៉ុន្តែដោយសារតែវិបត្តិសេដ្ឋកិច្ច គ្រួសារជាច្រើនបានបង្ខំចិត្តរស់នៅក្នុងផ្ទះតែមួយដើម្បីបញ្ចៀសនូវភាពជាទុរគតជនរបស់ពួកគេ។

ប្រភពដដែលនោះ ក៏បានដកស្រង់តួលេខពីនាយកដ្ឋាន លំនៅស្ថាន និងអភិវឌ្ឍន៍ទីក្រុងរបស់សភា ក៏បានឱ្យដឹងថា កាលពីឆ្នាំ២០០៧ ចំនួនពលរដ្ឋអាមេរិកដែលរស់នៅផ្តុំគ្នា មានត្រឹមតែ១៣១០០០គ្រួសារទេ។ ប៉ុន្តែក្នុងឆ្នាំ២០០៨ នេះបានឡើងដល់ ១៥៩០០០គ្រួសារ។ ហើយក្នុងឆ្នាំ២០០៩ កន្លងទៅចំនួនបានឡើងរហូតដល់ទៅ ១៧០០០០គ្រួសារ។

ផ្អែកតាមតួលេខនេះ ប្រភពដដែលបានឱ្យដឹងថា មានប្រជាពលរដ្ឋជាច្រើនបានធ្លាក់ខ្លួនប្រឈមមុខនឹងការក្លាយខ្លួនជាទុរគតជន។ ហើយដោយសារតែកង្វះខាតបណ្តាញគាំពារ ពួកគេអាចនឹងក្លាយទៅជាអ្នកគ្មានផ្ទះសម្បែងជាបន្តបន្ទាប់ ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ចនេះ។

## ស្ពានអាកាសទីមួយត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

សំណង់ជាប្រវត្តិសាស្ត្រមួយ សម្រាប់ប្រជាពលរដ្ឋ នៅក្នុងទីក្រុងភ្នំពេញ គឺស្ពានអាកាស បានត្រូវសម្ពោធដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០ ក្រោមអធិបតីភាពរបស់សម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ រាជរដ្ឋាភិបាលកម្ពុជា។

ស្ពាននេះមានទីតាំងនៅក្បាលថ្នល់ដែលត្រូវបានកសាងឡើងក្រោមទឹកប្រាក់ ៧លានដុល្លារ។ ស្ពាននេះត្រូវបានតភ្ជាប់ជូនអ្នកដំណើរដើម្បីសម្រួលចរាចរណ៍ និងបញ្ចៀសការកកស្ទះនៅលើផ្លូវជាតិលេខ២ និងមហាវិថីនរោត្តម។ ស្ពាននេះគឺមានបណ្តោយ ៣០៨ ម៉ែត្រ ទទឹង ១៤,២០ ម៉ែត្រ និងកម្ពស់ ៥,២០ ម៉ែត្រ។

នេះគឺជាសមិទ្ធផលថ្មីមួយរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងដំណើរការអភិវឌ្ឍប្រទេសជាតិ។

បន្ទាប់ពីស្ពានសម្ពោធដាក់ឱ្យប្រើប្រាស់នោះ អាជ្ញាធរទីក្រុងភ្នំពេញក៏បានប្រកាសពីការរៀបចំកសាងស្ពានអាកាសពីរកន្លែងទៀតឆ្លងកាត់ផ្លូវសហព័ន្ធរុស្ស៊ី។ មួយកន្លែងភ្ជាប់ពីតំបន់បឹងកក់ទៅតំបន់ក្តាន់ពីរនៅជិតទីស្តីការគណៈរដ្ឋមន្ត្រី ហើយនិងស្ពានមួយទៀត នឹងត្រូវសាងសង់នៅត្រង់ផ្លូវបំបែកស្តុបពេទ្យលោកសង្ឃ។



Photo : P. Samphy

July-2010.qxd 7/6/2010 9:00 AM Page 9



# ការីតាសប្រារព្ធខួប ២០ឆ្នាំ ក្នុងការបម្រើប្រជាជនកម្ពុជា

**ជាត សំភី**

*មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជា បុគ្គលិកថ្នាក់ដឹកនាំអង្គការការីតាស និងអ្នកភូមិយ៉ាងច្រើនកុះករ បានចូលរួមពិធីរំឭកខួប ២០ឆ្នាំនៃអង្គការការីតាសនៅកម្ពុជា នៅសណ្ឋាគារភ្នំពេញកាលពីថ្ងៃទី១៥ ខែមិថុនា។*

*លោកជំទាវបណ្ឌិត ម៉ែន សំអន ជាឧបនាយករដ្ឋមន្ត្រីប្រចាំការនៃរាជរដ្ឋាភិបាលកម្ពុជាធ្វើជាអធិបតីភាពក្នុងព្រឹត្តិការណ៍នោះ។*


Photo : L. Sovanna

**លោកអភិបាលអេមីល ដេតម្ប ទទួលមេដាយគុណបំណាច់កសាងជាតិពីរាជរដ្ឋាភិបាល**

លោកគីម រតនា ជានាយកប្រតិបត្តិនៃអង្គការការីតាសកម្ពុជា មានប្រសាសន៍ថា រយៈពេល ២០ ឆ្នាំ អង្គការការីតាស បានចំណាយ ២៤លាន ដុល្លារ លើគម្រោងជាច្រើន ដើម្បីជួយប្រជាជនកម្ពុជា ដូចជា ការលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទសុខភាពភ្នែក សុខភាពសហគមន៍ សុខភាពផ្លូវចិត្ត ថែទាំអ្នកផ្ទុកមេរោគអេដស៍ សុខភាពទណ្ឌិត ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនក្រីក្រ និងការឆ្លើយតប និងការត្រៀមបង្ការគ្រោះមហន្តរាយ...។

លោកជំទាវម៉ែនសំអនមានប្រសាសន៍ថា កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំយុទ្ធសាស្ត្រជាច្រើនដើម្បីការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ អង្គការការីតាស បានធ្វើកម្មវិធីជាច្រើន ដូចជាការលើកកម្ពស់កសិកម្ម ការជួយលើការអប់រំ និងការថែទាំសុខភាព....។ សកម្មភាពទាំងនេះជួយគាំទ្ររដ្ឋាភិបាលដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅក្នុងប្រទេសផងដែរ។

លោកគីម រតនា ក៏គូសបញ្ជាក់ថា នៅក្នុងផែនការ សម្រាប់ ៥ឆ្នាំ តទៅមុខ អង្គការការីតាសនឹងមានគម្រោងចំណាយ ១៦លាន ដុល្លារទៀត ដើម្បីគាំទ្រកម្មវិធីរបស់ខ្លួន។


Photo : L. Sovanna

**លោកជំទាវបណ្ឌិតម៉ែន សំអន និងលោកអភិបាលគីកេ ទស្សនាផលិតផលផ្សេងៗដូចជាផលិតផលកសិកម្ម ឬសិប្បកម្មដែលធ្វើឡើងដោយអ្នកភូមិក្រោមការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍របស់អង្គការការីតាស**

លោកអភិបាលនៃភូមិភាគកាតូលិកបាត់ដំបង គីកេ ហ្វិការេដូ និងជាអធិបតីនៃអង្គការការីតាសកម្ពុជាអះអាងថា: "ការីតាសគឺជាដៃស្តាំរបស់ព្រះសហគមន៍នៅកម្ពុជា"។ លោកអភិបាលក៏បានបន្តថា: "អង្គការការីតាសបានបង្កើត ដូចជាកម្មវិធីអភិវឌ្ឍន៍សហគមន៍ដើម្បីលើកទឹកចិត្តប្រជាជនក្រីក្រប្រកបរបរចិញ្ចឹមជីវិតកាន់តែប្រសើរ។ ជាលទ្ធផល ពួកគាត់មានលទ្ធភាពគ្រប់គ្រាន់ដើម្បីអភិវឌ្ឍខ្លួនឯង និងផលិតចេញជាផលិតផលផ្សេងៗ"។

នៅក្នុងថ្ងៃប្រារព្ធពិធី អ្នកភូមិមកពីខេត្តទាំង៩ នៅទូទាំងប្រទេស ដែលអង្គការការីតាសបានធ្វើសកម្មភាព ក៏បាននាំមកជាផលិតផលកសិកម្ម និងសិប្បកម្មរបស់ពួកគេ មកចូលរួមដើម្បីធ្វើការតាំងពិព័រណ៍ និងលក់ជូនភ្ញៀវកិត្តិយសផលដែរ"។

លោកញឹក សារ៉ុន គឺជាអ្នកភូមិម្នាក់មកពីខេត្តសៀមរាប។ អ្នកភូមិអាយុ ៤៩ឆ្នាំរូបនេះ និយាយថា អង្គការការីតាស បានមានវត្តមានក្នុងភូមិរបស់គាត់តាំងពីឆ្នាំ២០០២។ លោកក៏បន្តថា: "បុគ្គលិកការីតាសបានជួយយើងឱ្យបង្កើតក្រុមសន្សំលុយ។ ដូច្នេះយើងអាចមានប្រាក់ដើម្បីជួយគាំទ្រដល់ការធ្វើស្រែ នៅរដូវប្រាំង និងរដូវវស្សា ធ្វើការចិញ្ចឹមមាន់ និងដាំដំណាំផ្សេងៗ ដើម្បីទ្រទ្រង់ជីវភាព"។ លោកបានបញ្ជាក់បន្ថែម: "បន្ទាប់ពីនោះមក ជីវភាពរបស់យើងក៏កាន់តែប្រសើរឡើង"។

## ប្រវត្តិអង្គការការីតាសនៅកម្ពុជា

នៅឆ្នាំ១៩៧២ ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាបានបង្កើតគណៈកម្មការជំនួយដើម្បីជួយជនរងគ្រោះដោយសារសង្គ្រាម។ គណៈកម្មការជំនួយនេះត្រូវបានទទួលឈ្មោះជាអង្គការការីតាសកម្ពុជា។ អង្គការការីតាសបានដំណើរការរហូតដល់ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមចូលក្តាប់អំណាច។

នៅថ្ងៃទី២២ មីនា ១៩៩០ អង្គការការីតាសនៅកម្ពុជាបានបង្កើតឡើងវិញជាផ្លូវការដោយលោកអភិបាលអេមីល ដេតម្ប ក្រោមជំនួយឧបត្ថម្ភពីអង្គការការីតាសអន្តរជាតិ អង្គការការីតាសបារាំង ជាមួយនិងកិច្ចសហប្រតិបត្តិការជាមួយនិងរដ្ឋាភិបាលកម្ពុជា។

July-2010.qxd 7/6/2010 9:00 AM Page 10



# ឯកអគ្គរាជទូតសម្តេចប៉ាបសាលវ៉ាទ័រ ពេណ្ណាស៊ីរ

**ខាន់ ភីរម្យ**

លោកសាលវ៉ាទ័រ ពេណ្ណាស៊ីអូជាឯកអគ្គរាជទូតសម្តេចប៉ាបប្រចាំនៅព្រះរាជាណាចក្រកម្ពុជាបានបញ្ចប់បេសកកម្មការទូតរបស់លោក ក្នុងប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍ បន្ទាប់ពីសម្តេចប៉ាបបេណេឌីកទី១៦ បានតែងតាំងរូបលោក ធ្វើជាឯកអគ្គរាជទូតរបស់បុរីវ៉ាទីកង់ប្រចាំនៅប្រទេសឥណ្ឌាកាលពីថ្ងៃទី៨ ខែឧសភាកន្លងទៅ។

នៅក្នុងខណៈពេលដែលអាណត្តិការទូតរបស់លោកត្រូវបានបញ្ចប់។ លោកក៏បានធ្វើដំណើរមកកាន់ប្រទេសកម្ពុជា កាលពីថ្ងៃទី២៩ មិថុនា ដើម្បីជួបសម្តែងនូវការគួរសមនិងជម្រាបលាថ្នាក់ដឹកនាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងធ្វើការរៀបចំពិធីជម្រាបលាសមាជិកព្រះសហគមន៍កាតូលិក។

លោកសាលវ៉ាទ័រ ពេណ្ណាស៊ីអូ ត្រូវបានគេតែងតាំងធ្វើជាឯកអគ្គរាជទូតសម្តេចប៉ាបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ហើយនិងបណ្តាប្រទេសមួយចំនួន នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដូចជាថៃ សិង្ហបុរី ភូមា ឡាវ ម៉ាឡេស៊ី និងប្រ៊ុយណេ តាំងតែពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៣។

ក្នុងរយៈពេលអាណត្តិការទូតរបស់លោកប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា លោកបានចូលរួមសកម្មភាពមនុស្សធម៌ជំរុញការអភិវឌ្ឍនិងកិច្ចការកសាងព្រះសហគមន៍ យ៉ាងច្រើន នៅក្នុងប្រទេសកម្ពុជា។ លោកក៏បានជំរុញឱ្យព្រះសហគមន៍ មានទំនាក់ទំនងល្អជាមួយនឹងសាសនានានាក្នុងប្រទេសកម្ពុជាដើម្បីរស់នៅប្រកបដោយសុខដុមរមនា និងសន្តិភាព ជាពិសេស គឺទំនាក់ទំនងការទូតរវាងបុរីវ៉ាទីកង់ និងព្រះរាជាណាចក្រកម្ពុជា។

លោកអន់តូនី សាមីស៊ូសៃរាជ អភិបាល នៃព្រះសហគមន៍ភូមិភាគកំពង់ចាម បានមានប្រសាសន៍ថា អាណត្តិរបស់ឯកអគ្គរាជទូតមានតែ៣ឆ្នាំទេ តែលោកសាលវ៉ាទ័រ ពេណ្ណាស៊ីអូ បាននៅជាមួយពួកយើងរហូតដល់ទៅ៦ឆ្នាំ ហើយលោកក៏តែងតែចូលរួមសកម្មភាពនៃព្រះសហគមន៍ជាបន្តបន្ទាប់ទាំងបីភូមិភាគ។ លោកអភិបាលបាន បញ្ជាក់ថា: "ខ្ញុំចាំបានថា កាលពី៥ឆ្នាំមុន ព្រះសហគមន៍នៅភូមិភាគកំពង់ចាមយើង រៀបចំពិធីបុណ្យមួយនៅព្រះសហគមន៍កោះរកា។ បុណ្យនេះសំខាន់សម្រាប់យើងតែសម្រាប់លោកឯកអគ្គរាជទូត គឺអាចមិនសំខាន់ដោយសារតែលោកមានភារៈកិច្ចច្រើន។ ទោះបីជាយ៉ាងណា តបតាមការអញ្ជើញរបស់យើង លោកក៏បានចូលរួម"។

លោកអភិបាលបានបន្តទៀតថា ក្រៅពីចូលរួមជាមួយយើងនៅភូមិភាគផ្សេងៗដូចជាភ្នំពេញ និងបាត់ដំបង។ លោកតែងចូលរួមគ្រប់សកម្មភាពធំៗរបស់ព្រះសហគមន៍ ដូចជាសម្ពោធមន្ទីរពេទ្យ នៅខេត្តតាកែវ និងសម្ពោធវិទ្យាស្ថានសន្តប៉ូល។

ក្នុងខណៈពេល លោកសាលវ៉ាទ័រ ពេណ្ណាស៊ីអូ ត្រូវធ្វើដំណើរទៅទទួលភារៈកិច្ចថ្មីនៅក្នុងប្រទេសឥណ្ឌា ដែលជាប្រទេសមួយមានប្រជាពលរដ្ឋ ជាងមួយពាន់លាននាក់ មានអភិបាលនៃព្រះសហគមន៍ចំនួនជាង ១០០ភូមិភាគ និងមានភាសាច្រើននោះ លោកអភិបាលអន់តូនីបានសម្តែងការជូនពរលោកអគ្គរាជទូតទទួលបានជោគជ័យថ្មីៗ ក្នុងបេសកកម្មការទូតថ្មីនៅក្នុងប្រទេសឥណ្ឌា។

លោកសាលវ៉ាទ័រ ពេណ្ណាស៊ីអូ កើតនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៥២ នាទីក្រុងម៉ារ៉ាណូណា ប្រទេសអ៊ីតាលី។លោកបានទទួលអគ្គសញ្ញាតែងតាំងឱ្យជាបូជាចារ្យនៅថ្ងៃទី០៨ខែកញ្ញា ឆ្នាំ១៩៧៦។ លោកធ្លាប់បានបម្រើការងារជាទូតរបស់សម្តេចប៉ាបនៅក្នុងប្រទេសជាច្រើនដែរ រួមមានប្រទេសប៉ាណាម៉ា អេត្យូពីរ អូស្ត្រាលី ទួរគី អេហ្ស៊ីប យូហ្គោស្លាវី និងនៅប្រទេសអៀកឡង់។ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ លោកត្រូវបានតែងតាំង ធ្វើជាអគ្គរាជទូតរបស់សម្តេចប៉ាបនៅក្នុងប្រទេសរ៉ូវ៉ាន់ដា ហើយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៣ ក៏ត្រូវតែងតាំងនៅក្នុងតំណែងជាអគ្គរាជទូតសម្តេចប៉ាបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ហើយនិងបណ្តាប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍។










July-2010.qxd 7/6/2010 9:01 AM Page 11

# អ្នបញ្ចប់បេសកកម្មនៅព្រះរាជាណាចក្រកម្ពុជា








Photos : CSC









# ព័ត៌មានព្រះសហគមន៍កាតូលិក

# បុណ្យគោរពព្រះកាយ និងព្រះលោហិតព្រះគ្រីស្តនៅបាត់ដំបង

**ភីរុណា**

លោកអភិបាលគីកេ ហ្វីហ្គារេដូ ប្រចាំភូមិភាគបាត់ដំបង មានប្រសាសន៍ថា: "នេះគឺជាពិធីបុណ្យដែលរំឭកយើង អំពីអត្ថន័យនៃការសោយទិវង្គតរបស់ព្រះយេស៊ូដែលមានព្រះហឫទ័យមេត្តា ករុណា និងជាស្ពានទាំឱ្យយើងទៅឯព្រះបិតា"។

នៅថ្ងៃទី៦ ខែមិថុនា ព្រះសហគមន៍បាត់ដំបង រៀបចំពិធីបុណ្យគោរពព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត ដែលជាពិធីបុណ្យមួយដែលមានអត្ថន័យសំខាន់សម្រាប់គ្រីស្តបរិស័ទម្នាក់ៗក្នុងការបង្ហាញជំនឿរបស់ខ្លួនដល់អ្នកដទៃ។

កញ្ញាប្រេច ស្រីនុច មកពីព្រះសហគមន៍ និគម និយាយថា ពិធីបុណ្យគោរពព្រះកាយព្រះលោហិតព្រះគ្រីស្តពិតជាមានអត្ថន័យសំខាន់ សម្រាប់កញ្ញា ដ្បិតក្បួនដង្ហែព្រះកាយព្រះលោហិតព្រះគ្រីស្ត បានធ្វើឱ្យកញ្ញានឹកទៅដល់សកម្មភាពរបស់ព្រះយេស៊ូ ដែលត្រូវគេដង្ហែចេញអំពីក្រុងយេរូសាឡឹម ដើម្បីរំដោះបាបដល់បុត្រធីតារបស់ព្រះអង្គ។

លោកស្រីរី វ័យ៤០ឆ្នាំ ដែលមកពីព្រះសហគមន៍ ច្រាបវាល បន្ថែមថា អ្វីដែលសំខាន់នោះគឺព្រះជាម្ចាស់ ចង់ឱ្យបុត្រធីតារបស់ព្រះអង្គ ចេះរស់នៅជាមួយនិងសេចក្តីស្រលាញ់ និងធម៌មេត្តាករុណា។ ហេតុដូច្នេះហើយ សូមអស់បងប្អូន និងយើងដែលជាគ្រីស្តបរិស័ទត្រូវចេះពឹងផ្អែកជីវិតទាំងស្រុងលើគម្រោងការរបស់ព្រះជាម្ចាស់។

នាពិធីបុណ្យគោរពព្រះកាយ ព្រះលោហិតព្រះគ្រីស្តមានគ្រីស្តបរិស័ទចូលរួមសរុបប្រមាណ៣៥០នាក់ មកពីព្រះសហគមន៍ ច្រាបវាល តាហែន ស្ទឹង និងនិគមនៅក្នុងភូមិភាគបាត់ដំបង។




គ្រីស្តបរិស័ទដង្ហែក្បួនគោរពព្រះកាយ និងព្រះលោកហិតព្រះគ្រីស្ត ដើម្បីសម្តែងជំនឿដ៏វិសុទ្ធចំពោះព្រះអង្គ

**យោងតាមស្មារតីអង្គប្រជុំក្រុមលោកអភិបាលនៃព្រះសហគមន៍កាតូលិកនៅកម្ពុជា កាលពីថ្ងៃទី១៤ ខែមិថុនាកន្លងទៅ បានសម្រេចបែងចែកកិច្ចការទទួលខុសត្រូវលើគណៈកម្មការអន្តរភូមិភាគជូនលោកអភិបាលដូចខាងក្រោម:**

**១. គណៈកម្មការអប់រំជំនឿ**
លោក អន់តូនីសាមី ស៊ូសៃរាជ

**២.ព័ត៌មានព្រះសហគមន៍កាតូលិក (ស៊ី អេស ស៊ី)**
លោក អូលីវីយេ ជ្មិតហស្លេរ

**៣. គណៈកម្មការពិធីបុណ្យ**
អន់តូនីសាមី ស៊ូសៃរាជ

**៤. គណៈកម្មការសង្គហៈ ឬមេត្តាករុណា**
លោក គីកេ ហ្វីការេដូ

**៥. ទេវវិទ្យាល័យ សន្តយ៉ូហាន ម៉ារី វីយ៉ាណេ**
លោក អូលីវីយេ ជ្មិតហស្លេរ

**៦. គណៈកម្មការអប់រំចំណេះទូទៅ**
លោក អូលីវីយេ ជ្មិតហស្លេរ

**៧. គណៈកម្មការកិច្ចការយុវជន**
លោក អូលីវីយេ ជ្មិតហស្លេរ

**៨. គណៈកម្មការសន្ទនាជាមួយសាសនាផ្សេងៗ**
លោក គីកេ ហ្វីការេដូ

**៩. គណៈកម្មការទំនាក់ទំនងជាមួយរដ្ឋាភិបាល**
លោកអូលីវីយេ ជ្មិតហស្លេរ

**១០. គណៈកម្មការទំនាក់ទំនងជាមួយក្រុមលោកអភិបាលអាស៊ី**
លោកគីកេ ហ្វីការេដូ

## Bishops In-Charge of the Episcopal Commissions:

**1- Episcopal Commission for Catechetical**

***Person In-charge:*** Msgr. Antonysamy Susairaj, MEP

**2- Episcopal Commission for Catholic Social Communications**

***Person In-charge:***

Msgr. Olivier Schmitthaeusler, MEP

**3- Episcopal Commission for Liturgy**

***Person In-charge:***

Msgr. Antonysamy Susairaj, MEP

**4- Episcopal Commission for the Charity - Caritas**

***Person In- Charge:***

Msgr. Kike Figaredo, SJ

**5- Major Seminary St. John Marie Vianney**

(Include: Emmanuel and Samuel Group)

***Person In-charge:*** Msgr. Olivier Schmitthaeusler, MEP

**6- Episcopal Commission for Educations**

***Person In-charge:*** Msgr. Olivier Schmitthaeusler , MEP

**7- Episcopal Commission for Youth**

***Person In-charge:***

Msgr. Olivier Schmitthaeusler, MEP

**8- Episcopal Commission for the Inter-religious Relations & Ecumenism**

***Person In-charge:***

Msgr. Kike Figaredo, SJ

**9- Relations with Government**

***Person In-charge:***

Msgr. Olivier Schmitthaeusler, MEP

**10- Relations with FABC**

***Person In-charge:*** Msgr. Kike Figaredo, SJ

July-2010.qxd 7/6/2010 9:01 AM Page 13



# អង្គការមនុស្សលោកថ្មីទទួលមេដាយមាសការងារពីរាជរដ្ឋាភិបាល

កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ អង្គការមនុស្សលោកថ្មី ឬ **(New Humanity)** បានអញ្ជើញចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយ ច្បាប់ស្តីអំពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងផែនការសកម្មភាពស្តីអំពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារមីននិងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម ។

នៅក្នុងឱកាសនៃអង្គសិក្ខាសាលានេះ ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា បានផ្តល់មេដាយ កិត្តិយសជូនតំណាងអង្គការ ដែលមានស្នាដៃឆ្នើមសម្រាប់ការងារពិការភាព ។ ក្នុងចំណោមអង្គការឆ្នើមទាំងនោះ អង្គការមនុស្សលោកថ្មីបានទទួលនូវមេដាយមាស សម្រាប់ការងាររបស់ខ្លួន ដែលបានជួយដល់កុមារពិការផ្នែកខួរក្បាល និងសតិបញ្ញាអន់ថយ ។

នៅក្នុងឱកាសនោះដែរ អង្គការមនុស្សលោកថ្មីក៏បានទទួលនូវប្រកាសនីយប័ត្រ គ្រឿងឥស្សរិយយសការងារដែលចុះហត្ថលេខា ដោយសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន មានខ្លឹមសារថា ឥស្សរិយយសការងារ ថ្នាក់មេដាយមាសនេះ ផ្តល់ជូនអង្គការមនុស្សលោកថ្មី ដែលមានស្នាដៃល្អ ក្នុងការងារសហការអង្គការជាតិ-អន្តរជាតិលើការងារពិការភាព និងការស្តារកាយសម្បទា និងដើម្បីជាសក្ខីភាពនៃការដឹងគុណរបស់រាជរដ្ឋាភិបាលកម្ពុជា និងអស់បណ្តារាស្ត្រខ្មែរ ។

**មនុស្សលោកថ្មី**



Photo : New Humanity

លោកអ៊ែរវេ រ៉ូគីប្លង់ នាយកអង្គការមនុស្សលោកថ្មីប្រចាំប្រទេសកម្ពុជា ទទួលមេដាយពីឯកឧត្តមអ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# “យើងត្រូវរស់នៅជាប់ជាមួយព្រះជាម្ចាស់”

មនុស្សប្រហែលជាង ២០០នាក់ បានមកជួបជុំគ្នាដើម្បីការបិទឆ្នាំបូជាចារ្យនៅក្នុងព្រះវិហារសន្តយ៉ូសែបផ្សារតូច រាជធានីភ្នំពេញ ក្រោមអធិបតីភាពរបស់លោកអភិបាលឧបត្ថម្ភក អូលីវីយេ ឝ្មិតហស្លេរ នៃព្រះសហគមន៍ភូមិភាគភ្នំពេញ ជាមួយលោកអភិបាល ដែលមកពីភូមិភាគ ពីរផ្សេងទៀត និងអស់លោកបូជាចារ្យប្រមាណជា ២៥អង្គ ។

“បិទឆ្នាំបូជាចារ្យ គឺមិនមែនមានន័យថា យើងទាំងអស់គ្នាឈប់អធិដ្ឋានសម្រាប់លោកបូជាចារ្យនោះទេ ។” នេះជាប្រសាសន៍របស់លោកអភិបាល អូលីវីយេទៅកាន់អ្នកចូលរួមក្នុងអង្គពិធី ។

លោកក៏បានលើកឡើងដែរថា ជីវិតរបស់យើងជាគ្រីស្តបរិស័ទត្រូវរស់នៅឱ្យជាប់ជាមួយព្រះជាម្ចាស់ ទោះបីជាយើងមិនខ្វះខាតក្នុងការរស់នៅ ក៏ដោយ ។ លោកក៏បានសង្កត់ធ្ងន់ថា: “យើងត្រូវសួរខ្លួនឯងថា តើជីវិតរបស់យើងមានអត្ថន័យដែរឬទេ ប្រសិនបើយើងគ្មានវត្តមានរបស់ព្រះជាម្ចាស់?”

ឆ្នាំបូជាចារ្យត្រូវបានប្រារព្ធធ្វើពេញមួយឆ្នាំក្នុងព្រះសហគមន៍កាតូលិកទូទាំងសកលលោកចាប់ពីខែមិថុនា ឆ្នាំ២០០៩ ដល់ ខែមិថុនា ឆ្នាំ ២០១០ ។

អស់រយៈពេលមួយឆ្នាំ ព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា បានរៀបចំនូវកម្មវិធីអធិដ្ឋាន រៀងរាល់សប្តាហ៍ សម្រាប់អស់លោកបូជាចារ្យនៅពេលបញ្ចប់ពិធីថ្វាយអភិបូជា ។

**កែវ កញ្ញា**

# យុវសិស្សសិង្ហបុរី ៣៤នាក់ ចុះកម្មសិក្សានៅកំពង់ចាម

**អ៊ឹម សុខន**

យុវជន ដែលជាយុវសិស្សចំនួន៣៤នាក់ ជាជនជាតិសិង្ហបុរីបានចុះមកធ្វើកម្មសិក្សាក្នុងប្រទេសកម្ពុជា ។ ក្រុមនេះ អាចហៅម្យ៉ាងទៀតថា វ៉ាយ អ៊ីម ស៊ី អេដោយមានការដឹកនាំសាស្ត្រាចារ្យរបស់ក្រុមចំនួន ៣រូប ផងដែរ ។

តាមប្រសាសន៍របស់អ្នកស្រីរ៉ូសប្រធាននៃក្រុមសន្ទាំងសង់ ដឺ ប៉ូល ក៏បានរៀបរាប់ឱ្យដឹងថា កម្មសិក្សារបស់យុវសិស្សទាំងនេះ មានអត្ថន័យ មិនត្រឹមតែជាការធ្វើដំណើរសិក្សាស្វែងយល់ពីប្រទេសកម្ពុជាប៉ុណ្ណោះទេ ។ ប៉ុន្តែនេះជាដំណើរមនុស្សធម៌សម្រាប់ផ្តល់ជូនសិស្សានុសិស្សសាលាបឋមសិក្សា ហ៊ុន សែន កកោះស្ថិតនៅឃុំកោះរកា នៅក្នុងខេត្តកំពង់ចាម ដែលបានទទួលរងការខូចខាតនូវអគារសិក្សាចំនួន ២ខ្នង ដោយសារការបាក់នូវច្រាំងទន្លេ ក្នុងនោះមានអគារថ្ម១ខ្នង និងឈើ១ខ្នង ។

នេះជាកម្មសិក្សាមនុស្សធម៌ជាលើកទី២ របស់ក្រុមយុវជនសិង្ហបុរី ដែលហៅថា វ៉ាយ អ៊ីម ស៊ី អេ មកកាន់ព្រះសហគមន៍ កាតូលិកនៅក្នុង ភូមិភាគកំពង់ចាម ។ ពួកគេមកជួយជួសជុលសាលាបឋមសិក្សា ហ៊ុន សែន នៅកកោះ ដែលសកម្មភាពនេះបានចាប់ផ្តើមធ្វើនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១០ ។ ជាមួយគ្នានេះ ក៏មានការសាងសង់បណ្ណាល័យបឋមសិក្សាជូនសិស្សានុសិស្សនៅទីនោះផងដែរ ។

អ្នកស្រីរ៉ូសបានបញ្ជាក់ឱ្យដឹងទៀតថា ការសាងសង់បណ្ណាល័យនេះ ប្រៀបបានទៅនឹងការសាងនូវប្រភពចំណេះដឹង ។ អ្នកស្រីរ៉ូសបន្តថា គ្រប់សាលារៀនទាំងអស់ គួរតែមានបណ្ណាល័យ មិនថាជាថ្នាក់កម្រិតណាឡើយ ។ អ្នកស្រីនិយាយទៀតថា ម្យ៉ាងបណ្ណាល័យក៏ជាកន្លែងមួយ ដែលអាចធ្វើការទាក់ទាញនូវចំណាប់អារម្មណ៍របស់សិស្សានុសិស្ស និងមាតាបិតា ឬអាណាព្យាបាលរបស់សិស្ស ក្នុងការបញ្ជូនកូនរបស់ពួកគេមកទទួលការអប់រំ ។

សូមបញ្ជាក់ថា សកម្មភាពនេះក៏បានបញ្ចប់នៅថ្ងៃអង្គារ ទី៨ ខែមិថុនា នេះ ។

**អ៊ឹម សុខន**

July-2010.qxd 7/6/2010 9:01 AM Page 14



# ពិធីរំឭក ខួប៥ឆ្នាំ នៃសម្តេចប៉ាប និងខួបលោកអូលីវីយេ

លី សុវណ្ណា

*អបអរសាទររំឭកខួបលើកទី៥ របស់សម្តេចប៉ាប បេណេឌីកទី១៦ ក្នុងងារជាអភិបាលព្រះសហគមន៍កាតូលិកក្រុងរ៉ូម និងពិធីខួបកំណើតលោកអូលីវីយេ ។*



ពិធីថ្វាយអភិបូជារំឭកខួបតំណែង ៥ឆ្នាំ របស់សម្តេចប៉ាប



លោកអភិបាលអូលីវីយេ និងលោកអភិបាលអេមីល ជូនអំណោយលោកឯកអគ្គរាជទូតក្នុងពិធីរំឭកខួប៥ឆ្នាំសម្តេចប៉ាប




លោកអភិបាលភូមិបាត់ដំបង គីកេ ហ្វីការេដូ ជូនអំណោយលោកឯកអគ្គរាជទូតក្នុងពិធីជម្រាបលាលោក




ឯកឧត្តមអ៊ុច បូររិទ្ធ រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហ-ប្រតិបត្តិការអន្តរជាតិ និងលោកសាលវ៉ាទ័រ ពេណ្ណាស៊ីអូ (រូបឆ្វេង)



ពិធីអបអរសាទរខួបកំណើត ៥០ឆ្នាំ និងខួប ១២ឆ្នាំក្នុងជីវិតជាបូជាចារ្យរបស់លោកអភិបាលអូលីវីយេ នៅភូមិចំការទៀង ខេត្តតាកែវ



អបអរសាទរពិធីរំឭកខួប ៥ឆ្នាំ របស់សម្តេចប៉ាបជាអភិបាលព្រះសហគមន៍កាតូលិកក្រុងរ៉ូមនៅសណ្ឋាគារកំបូឌីយ៉ាណា

## បទយកការណ៍ព្រះសហគមន៍កាតូលិក

# ពិធីរំឭក ខួប៥ឆ្នាំ នៃសម្ដេចប៉ាបបេណេឌីកទី ១៦

**កែវ កញ្ញា**

ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា បានរៀបចំនូវពិធីអបអរសាទររំឭកខួបលើកទី៥ របស់សម្ដេចប៉ាប បេណេឌីកទី ១៦ ក្នុងងារជាអភិបាលព្រះសហគមន៍កាតូលិកក្រុងរ៉ូមនាថ្ងៃ២៩ មិថុនា។

កម្មវិធីនេះ បានប្រព្រឹត្តិទៅនៅសណ្ឋាគារ ខេមបូឌីយ៉ាណា រាជធានីភ្នំពេញក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ពីលោកអគ្គរាជទូតសម្ដេចប៉ាប ប្រចាំព្រះរាជាណាចក្រកម្ពុជា គឺលោកសាលវ៉ាទ័រ ពេណ្ណាស៊ីអូ លោកអភិបាលព្រះសហគមន៍កាតូលិកទាំងបីភូមិភាគនៅប្រទេសកម្ពុជា ឯកឧត្ដមរដ្ឋលេខា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្ដមជាតំណាងឱ្យក្រសួងធម្មការ ជាមួយនិងកិច្ចការសាសនា ឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត ជាអ្នកមុខ និងអ្នកការជាមន្ត្រី អង្គការសង្គមស៊ីវិលក្រៅរដ្ឋាភិបាល និងព្រមទាំងមានគ្រីស្ដបរិស័ទកាតូលិកចូលរួមយ៉ាងច្រើនកុះករទៀត។

លោកអ៊ុច បូររិទ្ធ រដ្ឋលេខាធិការនៃក្រសួងការបរទេសនិងសហប្រតិបត្តិអន្តរជាតិ ក៏បានថ្លែងក្នុងឱកាសនោះថា: "សូមឱ្យបន្តមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសកម្ពុជា និងបុរីវ៉ាទីកង់ឱ្យបានកាន់ប្រសើរឡើង"។ លោកឯកអគ្គរាជទូតក៏បានថ្វាយព្រះពរ ដល់ព្រះមហាក្សត្រ និងជូនពរដល់សម្ដេចប៉ាប ព្រមទាំងគ្រីស្ដបរិស័ទទាំងអស់ឱ្យមានសុខភាពល្អ និងមានសុភមង្គលជានិច្ចនិរន្តរ៍។

នៅក្នុងនោះដែរ លោកឯកអគ្គរាជទូត សាលវ៉ាទ័រ ពេណ្ណាស៊ីអូ បានថ្លែងអំណរគុណ ចំពោះអង្គទូតនានា ចំពោះកិច្ចការទំនាក់ទំនងជាផ្លូវការ ក្នុងនាមលោក ជាតំណាងរបស់សម្ដេចប៉ាប ប្រចាំនៅអាស៊ីអាគ្នេយ៍នេះ ដោយមានការសហការគ្នាយ៉ាងកក់ក្ដៅជាទីបំផុតរវាងព្រះសហគមន៍កាតូលិកនៅកម្ពុជា និងរាជរដ្ឋាភិបាល នៃប្រទេសនេះ និងអស់លោកទាំងអស់។

លោកក៏បានថ្លែងអំណរគុណសម្រាប់ការគាំទ្រនានារបស់រាជរដ្ឋាភិបាលកម្ពុជាដែលធ្វើឱ្យមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងបុរីវ៉ាទីកងបានកាន់តែល្អប្រសើរ។

ជាមួយគ្នានេះដែរ លោកឯកអគ្គរាជទូត ក៏បានថ្លែងអំណរគុណចំពោះគ្រីស្ដបរិស័ទកាតូលលិកក្នុងអំឡុងពេលដែល លោកទទួលខុសត្រូវនៅប្រទេសមួយនេះ រយៈពេល៧ឆ្នាំ កន្លងមកហើយ។

លោកក៏មានប្រសាសន៍ទៀតថា: "ខ្ញុំក៏សូមអរគុណចំពោះមិត្តភាពពីបងប្អូនទាំងអស់គ្នា និងការស្វាគមន៍យ៉ាងកក់ក្ដៅ ដែលបានជួយឧបត្ថម្ភគាំទ្រដល់បេសកកម្មរបស់ខ្ញុំ។ ដូចគ្នានេះដែរ ខ្ញុំសូមចាប់អារម្មណ៍ និងលើកទឹកចិត្តដោយសារតែជំនឿយ៉ាងអស្ចារ្យនេះ។" លោកបានបន្តថា: "ព្រះសហគមន៍កាតូលិកនៅកម្ពុជាគឺនៅក្មេងខ្ចី មានជីវិតរស់រវើក និងគួរជាទីស្រឡាញ់"។

សូមបញ្ជាក់ផងថា លោកសាលវ៉ាទ័រ ពេណ្ណាស៊ីអូ ត្រូវបានតែងតាំងជាឯកអគ្គរាជទូតសម្ដេចប៉ាប ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ហើយនិងបណ្ដាប្រទេសមួយចំនួន នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដូចជា ថៃ សិង្ហបុរី ភូមា ឡាវ ម៉ាឡេស៊ី និង ប្រ៊ុយណេ តាំងតែពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៣។

កាលពីថ្ងៃទី៨ ខែឧសភា កន្លងទៅ សម្ដេចប៉ាបបេណេឌីកទី១៦ បានតែងតាំងលោកជាឯកអគ្គរាជទូតរបស់បុរីវ៉ាទីកង់ប្រចាំនៅប្រទេសឥណ្ឌា។

សូមបញ្ជាក់ផងដែរថា ប្រទេសឥណ្ឌាមានប្រជាពលរដ្ឋជាងមួយពាន់លាននាក់ ក្នុងនោះ ក៏មានអភិបាលព្រះសហគមន៍ភូមិភាគ ចំនួនជាង ១០០ ភូមិភាគ និងមានភាសាជាច្រើនទៀត។




Photo : L. Sovanna

July-2010.qxd 7/6/2010 9:01 AM Page 16

## ជីវិតខ្ញុំ

# ជីវិតបងប្រុស ហ្វេរ៉ាណាន់ដូជាសក្ខីភាពនៃព្រះយេស៊ូគ្រីស្ត

**អ៊ឹម សុខន**


Photo : P. Samphy

បងប្រុសហ្វេរ៉ាណាន់ដូអាលេ អារ៉ាំងហ្គូល លើកឡើងថា : "ខ្ញុំចេះនិយាយខ្មែរបានតិចតួច។ ប៉ុន្តែខ្ញុំពិតជាសប្បាយចិត្ត ពីព្រោះខ្ញុំមានមិត្តភក្តិប្រុសស្រីចាស់ក្មេង និងអ្នកផ្សេងទៀតដែលគេស្វាគមន៍ និងផ្តល់ក្តីស្រលាញ់ដល់ខ្ញុំ ដូចជាសមាជិកគ្រួសាររបស់គេ។ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ណែនាំខ្ញុំឱ្យមកជួយបងប្អូននៅទីនេះ"។ នេះជាសំដីរបស់បងប្រុសនៅពេលបងប្រុសទទួលការតែងតាំង ជាឧបត្ថម្ភកនៅថ្ងៃទី១៣ខែមិថុនា ឆ្នាំ២០១០ នៅឯព្រះវិហារសន្ត យ៉ូសែប( ផ្សារតូច) រាជធានីភ្នំពេញ។

បងប្រុស ហ្វេរ៉ាណាន់ដូ អាលេ អារ៉ាំងហ្គូល ជនជាតិកូឡុំប៊ីជាសមាជិកក្រុមសាសនទូតយ៉ារ៉ូម៉ាល់។ បងប្រុសរូបនេះ បានមកប្រទេសកម្ពុជា ថ្ងៃទី១៣ខែមីនាឆ្នាំ២០០៩។ សព្វថ្ងៃគាត់កំពុងតែបម្រើនៅព្រះសហគមន៍កាតូលិកនៅតំបន់កំពត( ក្រោមការទទួលខុសត្រូវរបស់លោកបូជាចារ្យអ៊ុន សុន)។

បងប្រុសបានឱ្យដឹងថា ក្នុងឆ្នាំ២០០១ គាត់បានសម្រេចចិត្តចូលសិក្សាស្វែងយល់ពីជីវិតជាអ្នកបួស ហើយក៏បានទៅបម្រើបងប្អូននៅប្រទេសបូលីវៀ ( អាម៉េរិកខាងត្បូង) រយៈពេល២ខែ។

បងប្រុស បាននិយាយដែរថា វត្តមានរបស់ព្រះជាម្ចាស់ និងសំឡេងរបស់ទ្រង់បានហៅឱ្យរូបគាត់តាមរយៈការចូលរួមស្តាប់អត្ថបទព្រះគម្ពីរដំណឹងល្អ ឃើញសកម្មភាពបូជាចារ្យជួយដល់បងប្អូនតាមផ្លូវវិញ្ញាណ និងសង្គម និងការប្រកាសដំណឹងល្អឱ្យដល់បងប្អូនដែលមិនស្គាល់ព្រះជាម្ចាស់។ ទាំងនេះជារបៀប ដែលជួយរូបគាត់អាចស្វែងរកមាគ៌ាពិតសម្រាប់ខ្លួន និងតាមព្រះហឫទ័យនៃព្រះជាម្ចាស់។ បងប្រុសពោលថា: "ក្នុងអត្ថបទព្រះគម្ពីរដំណឹងល្អក៏មានសរសេរថា យើងត្រូវស្រលាញ់គ្នាទៅវិញទៅមកដូចខ្ញុំដែលបានស្រលាញ់អស់អ្នករាល់គ្នា។ នេះបង្ហាញថា យើងគ្រប់គ្នា គឺជាគ្រួសារដែលមានព្រះបិតា និងជំនឿតែមួយដែលបណ្តាលចិត្តរបស់យើងឱ្យមានសេចក្តីព្យាយាម ស្រលាញ់ និងការលះបង់សម្រាប់អ្នកឯងទៀត"។

បងប្រុសបញ្ជាក់ដែរថាពេលខ្លះបងប្រុសនឿយហត់ និងអស់កម្លាំងក្នុងការដើរលើផ្លូវនៃការត្រាស់ហៅត្បិតអ្វីដែលយើងធ្វើ គឺការលះបង់ ហើយមិនអាចតម្រូវចិត្តរបស់ខ្លួន ដែលចង់មាន និងចង់បានឡើយ។ ប៉ុន្តែសេចក្តីទាំងនេះអាចរលត់ទៅវិញនៅពេលដែលយើងស្តាប់ឮសំឡេងពិតរបស់ព្រះអង្គដែលចេញពីក្នុងដួងចិត្តរបស់ខ្លួនឯង តាមរយៈអ្នកដែលនៅជុំវិញខ្លួន មានបងប្អូន ក្រុមគ្រួសារ ហើយនិងមិត្តភក្តិ។ បងប្រុសបានសង្កត់ថា : "តែអ្វីដែលសំខាន់បំផុតសម្រាប់ជីវិតនៃការត្រាស់ហៅនេះ គឺការអធិដ្ឋានទូលអង្វរដល់ព្រះជាម្ចាស់ ក្នុងនាមជាបុត្រធីតា នៃព្រះអង្គ និងជាមនុស្សទន់ខ្សោយ"។

## ប្រតិទិនអភិបូជា

- **ភាសាខ្មែរ** : ព្រះវិហារសន្តយ៉ូសែបភ្នំពេញ (០១២ ៧៨២ ២៤១) ថ្ងៃច័ន្ទ-សៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក និងម៉ោង៥រសៀល។
  -កំពង់សោម (០១៦ ៨៤០ ៥៤០) ថ្ងៃច័ន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ : ល្ងាចម៉ោង៥។ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក។
  -សៀមរាប (០៦៣ ៩៦៥ ២៨០) ថ្ងៃអាទិត្យ : ម៉ោង៧:៣០ព្រឹក។ ថ្ងៃច័ន្ទ-ថ្ងៃព្រហស្បតិ៍ : ព្រឹក ៦:៣០ម៉ោង។ ថ្ងៃសុក្រ : ម៉ោង ៦:៣០ល្ងាច។
  -បាត់ដំបង (ពេទ្យយាយជី) ថ្ងៃអាទិត្យ : ម៉ោង ៨:០០ព្រឹក។ ថ្ងៃច័ន្ទ : ល្ងាច៦:០០។ ថ្ងៃអង្គារ-សុក្រ : ម៉ោង៦:១៥ ព្រឹក។
- **Français** : $1^{er}$ et $3^{ème}$ Samedi du mois à 5:30pm ; $2^{ème}$ et $4^{ème}$ Dimanche du mois à 11:00am; à l'église de St. Joseph, #1788B, RN5, PP.
- **English** : - Phnom Penh : Sunday at 10: 00 am; at St. Joseph Church (#1788B, NR5, PP); Saturday at 5: 00 pm, at World Vision Cambodia (#2 St 71, PP); - Sihaknouk Ville : Sunday at 5:00 pm; # Catholic Church St.12 13 Mattapheap; H/P: 016 840 540 (Fr. Werachai); - Siem Reap : Saturday at 6:30 pm; #Catholic Church, No 027 East River Side Street. - Battambang : Saturday: at 6:00 pm at Battamabang Church (Pet Yeaychi), Rumchek 1, Rattanak, H/P: 012 911 147 (Fr. Totet).

July-2010.qxd 7/6/2010 9:01 AM Page 17





Photo : S. Philong

# ទោសធ្ងន់ធ្ងរសម្រាប់វិន័យព្រះសង្ឃ គឺទោសបរាជិក

**ខាន់ ភីរម្យ**

"គម្ពីរព្រះត្រៃបិដកដែលមាន៨៤០០០ព្រះធម្មខណ្ឌ បានចែងថា ទោសវិន័យដែលធ្ងន់ធ្ងរបំផុតសម្រាប់ព្រះសង្ឃ គឺទោសបរាជិក។" នេះបើតាមព្រះសង្ឃដីកា របស់ព្រះភិក្ខុកែន ស្រេង។

ព្រះភិក្ខុ កែន ស្រេង បានមានព្រះសង្ឃដីកាថា នៅក្នុងព្រះពុទ្ធសាសនា មានគម្ពីរមួយគេហៅថាគម្ពីរព្រះត្រៃបិដក។នៅក្នុងគម្ពីរនោះ មានបែងចែកជាបីទៀត គឺគម្ពីរព្រះសូត្រមាន២១០០០ធម្មខណ្ឌ គម្ពីរព្រះអភិធម្ម មាន ៤២០០០ ធម្មខណ្ឌ និងព្រះវិន័យមានចំនួន២១០០ ព្រះធម្មខណ្ឌដែរ។

នៅក្នុងគម្ពីទាំងនេះទោសបញ្ញត្តធ្ងន់ធ្ងរបំផុតរបស់ព្រះសង្ឃ គឺបរាជិក។

ព្រះអង្គបានមានសង្ឃដីកាបន្តទៀតថា ទោសដែលបណ្តាលឱ្យព្រះសង្ឃត្រូវបរាជិកនោះ គឺមានបួន គឺទីមួយ ការលបលួចសេពមេថុន ឬក៏ការរួមភេទ។ ទី២ ទោសអួតគុណវិសេស គឺព្រះពុទ្ធលោកហាមមិនឱ្យព្រះសង្ឃអួតថា ចេះនេះ ចេះនោះ ហួសពីព្រះធម៌ឡើយ។ ទី៣ គឺទោសធ្វើមនុស្សឃាត ដោយព្រះពុទ្ធ លោកហាមឃាត់ដាច់ខាតការសម្លាប់។ ចំពោះទោសទី៤ គឺការលួចទ្រព្យសម្បត្តិពីអ្នកដទៃ។ ក្រៅពីនោះមានទោសចំនួន ១៣យ៉ាងទៀត។ ប៉ុន្តែពុំដល់ថ្នាក់ធ្ងន់ធ្ងរទេ ពោលគឺគ្រាន់តែជាការធ្វើពិន័យតែប៉ុណ្ណោះ។

បើយោងតាមសង្ឃដីការបស់ភិក្ខុកែន ស្រេង ដើម្បីបួសជាសង្ឃបាននោះ គឺបុគ្គលម្នាក់ៗ ត្រូវតែមានការយល់ព្រមអំពីសាមីខ្លួន ពីអាណាព្យាបាល ពីអាជ្ញាធរ និងអត់មានជាប់ជំពាក់នឹងទោសទណ្ឌណាមួយនៅក្នុងសង្គម។ ហើយបុគ្គល នោះទៀតសោត គឺទាល់តែមានកាយសម្បទាល្អ ហើយមុននឹងបួសត្រូវតែរៀនធម៌បួសជាមុនសិន។ ប៉ុន្តែរយៈពេលនៃការរៀននោះ គឺមិនមានកំណត់ទេ។

ព្រះភិក្ខុមានសង្ឃដីកាបន្ថែមថា ចំណុចដែលព្រះពុទ្ធទាមទារឱ្យអ្នកបួសមានកាយសម្បទាល្អនោះ មិនមែនមានន័យថា ព្រះអង្គរើសអើងទេ។ ប៉ុន្តែគឺដោយសារតែព្រះសង្ឃត្រូវរស់ដោយទឹកចិត្តជ្រះថ្លារបស់ពុទ្ធសាសនិក និងដោយការដើរបិណ្ឌបាត។

ព្រះភិក្ខុ បានមានសង្ឃដីកាបន្តទៀតថា ព្រះសង្ឃមានលោកនេន ឬសាមណេរ និងព្រះភិក្ខុ។ លោកនេនគោរពសិក្ខាបទចំនួន ៣០។ ហើយព្រះភិក្ខុគឺត្រូវគោរពសិក្ខាបទ (មាត្រាសីលវិន័យ) ទាំងអស់ ២២៧។

## អំណាន

### ម្ហូបក្នុងសង្គមខ្មែរ




គឺជាសៀវភៅដែលចងក្រងពីប្រភេទម្ហូបនិងរបៀបរបបហូបចុកតាមបែបជីវភាពសាមញ្ញរបស់អ្នកស្រុកតាមជនបទស្រុកស្រែចំការ។ មុខម្ហូបរបស់ខ្មែរមានច្រើនស្ទើររាប់ពុំអស់។ របៀបធ្វើក៏ខុសៗគ្នាតាមមុខនីមួយៗហើយសូម្បីម្ហូបដូចគ្នាក៏ធ្វើខុសប្លែកគ្នាតាមទម្លាប់ក្នុងគ្រួសារដែរ។

សៀវភៅនេះមានរូបភាពល្អៗ ហើយត្រូវបានគេបោះពុម្ពឡើង ជាពិសេស សម្រាប់ប្រមូលផ្តុំព័ត៌មាន និងរឿងរ៉ាវដែលទាក់ទងនឹងវប្បធម៌នៃការហូបចុកមួយចំនួនក្នុងសង្គមខ្មែរ។ ព័ត៌មានទាំងឡាយ គឺពឹងផ្អែកស្ទើរទាំងស្រុងលើការសាកសួរពីមនុស្សចាស់ៗជាច្រើននាក់ និងអ្នកដែលប៉ិនប្រសប់ធ្វើម្ហូបមួយចំនួន រួមទាំងការសង្កេតឃើញនូវសកម្មភាព ដែលគេធ្វើម្ហូបដោយផ្ទាល់ តាមផ្ទះ វត្តអារាម ឬទីកន្លែងផ្សេងៗទៀតផង។

សៀវភៅម្ហូបក្នុងសង្គមខ្មែរ មាន១៣៣ទំព័រ ហើយនិពន្ធដោយជាសោភារី។ សៀវភៅនេះបោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពផ្សាយរៃយំ និងលក់តម្លៃ២០០០០រៀល។



### ទន្សាយ ក្នុងព្រះខែ

នេះជារឿងមួយយ៉ាងល្បីក្នុងកម្រងរឿងព្រេងជប៉ុនភាគ២ ដែលមានអាយុច្រើនសតវត្សណាស់មកហើយ។ រឿងគឺនេះមានលំនាំប្រហាក់ប្រហែលនឹងរឿងខ្មែរយើងដែរ។ ហើយគេក៏តែងនិទានវាឱ្យកុមារតូចៗ ស្តាប់កំសាន្ត នៅមុនពេលគេង ឬពេលទំនេរ។

ទន្សាយក្នុងព្រះខែ និទានពីសម្លាញ់៣នាក់ ដែលមានទន្សាយ កញ្ជ្រោង និងស្វា។ ពួកគេស្រលាញ់គ្នាណាស់ និងចេះជួយអាសាគ្នាទៀតផង។ សត្វទាំងអស់ ក្នុងព្រៃស្ទើចសរសើរសម្លាញ់ទាំងបីនេះគ្រប់ៗគ្នា រហូតល្បីទៅដល់ព្រះឥន្ទ្រ។ ព្រះឥន្ទ្រចង់ដឹងថាតើរឿងនេះពិតឬយ៉ាងណា? ពីព្រោះទោះបីជាមនុស្សលោកក៏ដោយ ក៏ការរស់នៅនេះគឺអាស្រ័យ ជាមិត្តសម្លាញ់នឹងគ្នាបែបនេះ វាគឺជារឿងមួយពិបាកណាស់។ ដូច្នេះព្រះឥន្ទ្រក៏ប្រែកាឡា ជាតាចាស់ស្លូមមកសុំអាហារពីសត្វទាំងបី។ កញ្ជ្រោង និងស្វាក៏ចេញទៅរកអាហារយកមកឱ្យតាចាស់។ ប៉ុន្តែ ទន្សាយវិញ វាគ្មានបានអ្វីនឹងគេសោះ។ តើព្រះឥន្ទ្រគិតយ៉ាងម៉េចដែរ ចំពោះទង្វើរបស់ទន្សាយ ? តើទន្សាយ គឺពិតជាចេះជួយមិត្តភក្តិដូចគេនិយាយតៗគ្នាដែរឬទេ?

**ហេង ដារី**

July-2010.qxd 7/6/2010 9:01 AM Page 18

# ប្រវត្តិសាស្ត្រ

# បាល់ទាត់ពិភពលោក ព្រឹត្តិការណ៍កីឡាដ៏រំភើបបំផុត

**ជាត សំភី**

បាល់ទាត់ពិភពលោក ជាការប្រកួតជាលក្ខណៈ អន្តរជាតិ ដែលប្រព្រឹត្តិឡើងតាមធម្មតារយៈពេល ៤ឆ្នាំម្តង ។ ការប្រកួតដែលបង្កើតឡើងដំបូងដោយ លោកហ្ស៊ុល រីម៉េ (Jules Rimet) ជនជាតិបារាំង នៅឆ្នាំ១៩២៨ ត្រូវបានបើកចំហទៅដល់គ្រប់សហព័ន្ធបាល់ទាត់ទាំងអស់ ដែលទទួលស្គាល់ដោយសមាគមសហព័ន្ធបាល់ទាត់អន្តរជាតិហ្វីហ្វា (FIFA) ។

ការប្រកួតពានរង្វាន់បាល់ទាត់ពិភពលោកនៅ លើកទីមួយ រៀបចំធ្វើឡើង នៅឆ្នាំ១៩៣០ នៅឯ ប្រទេសអ៊ុយរូហ្គាយ Uruguay ប្រចាំទ្វីបអាមេរិក ខាងត្បូង ដែលជាប្រទេសទទួលនូវជ័យជម្នះពានរង្វាន់បាល់ទាត់ពិភពលោកលើកនោះតែម្តង ។

ការប្រកួតបាល់ទាត់ពិភពលោកធ្វើឡើងជាពីរ ដំណាក់កាល ។ ដំណាក់កាលទីមួយ ត្រូវបានរៀបចំ ដោយសម្ព័ន្ធសហព័ន្ធតាមទ្វីប ជាដំណាក់កាលដំបូង គេត្រូវជ្រើសរើសក្រុមបាល់ទាត់ខ្លាំងៗពីប្រទេស នានា នៅតាមទ្វីបនីមួយៗ ឱ្យចូលរួម នៅដំណាក់ កាលចុងក្រោយ ដែលប្រព្រឹត្តិទៅ នៅក្នុងប្រទេស ម្ចាស់ផ្ទះរៀបចំការប្រកួត ។ ទម្រង់សព្វថ្ងៃសម្រាប់ នៃដំណាក់កាលចុងក្រោយ មាន ៣២ក្រុម ពី ៣២ ប្រទេសដែលប្រកួតរយៈពេលប្រហែល ១ខែ ។

កន្លងមក មានប្រជាជាតិចំនួន៧ បានឈ្នះពាន រង្វាន់បាល់ទាត់ពិភពលោក ។ ប្រទេសប្រេស៊ីលតែ មួយគត់ ដែលបានចូលរួមគ្រប់ការប្រកួតពានរង្វាន់ បាល់ទាត់ពិភពលោក ហើយបានទទួលឯកទគ្គកម្ម ជ័យជម្នះជាមួយនិងការប្រកួតឈ្នះពានរង្វាន់បាល់ ទាត់ពិភពលោកចំនួន ៥ដង ។ ប្រទេសអ៊ីតាលីមាន ឈ្មោះល្បីផងដែរដោយឈ្នះពានរង្វាន់៤ដង ដែល ច្រើនជាងប្រទេសអាឡឺម៉ង់ម្តង ។ ក្រុមបាល់ទាត់ ប្រទេសអ៊ុយរូហ្គាយ បានឈ្នះពានរង្វាន់បាល់ទាត់ ពិភពលោកពីរដង ដូចគ្នានឹងប្រទេសអាហ្សង់ទីន ។ ចុងក្រោយ គឺប្រទេសបារាំង និងប្រទេសអង់គ្លេស ដែលឈ្នះពានរង្វាន់ម្តងម្នាក់ ។

ប្រទេសអ្នករៀបចំនូវការប្រកួតពានរង្វាន់បាល់ ទាត់ពិភពលោកត្រូវបានជ្រើសរើសដោយអង្គការ FIFA ។ ការប្រកួតបាល់ទាត់ពិភពលោក លើកនេះ ប្រព្រឹត្តិទៅនៅប្រទេសអាហ្វ្រិកខាងត្បូងពីថ្ងៃទី១ ១ ខែមិថុនា ដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១០ ។ ប្រទេសប្រេស៊ីល ក៏ត្រូវបានជ្រើសរើសដើម្បីទទួល នូវការប្រកួតពានរង្វាន់បាល់ទាត់ពិភពលោកនៅ លើកបន្ទាប់ គឺនៅឆ្នាំ២០១៤ ។

យោងតាមការគណនាពីវិបសាយកីឡាអង់គ្លេស ចំណូលដែលបានមក ពីការប្រកួតពានរង្វាន់ បាល់ទាត់ពិភពលោកឆ្នាំ២០១០នឹងឡើងដល់២,៧ កោដិអឺរ៉ូ (ឬ៣,៣កោដិដុល្លារ) ដែលនេះមានការ កើនឡើង៤៨% បើប្រៀបធៀបទៅនឹងការប្រកួត ពានរង្វាន់បាល់ទាត់ពិភពលោកនាឆ្នាំ២០០៦ នៅ ប្រទេសអាឡឺម៉ង ។ការផ្តល់នូវសិទ្ធិផ្សាយបន្តផ្ទាល់ តាមទូរទស្សន៍អាចរកចំណូលប្រហែល ១,៧កោដិ អឺរ៉ូ និងចំណូលពីកិច្ចការទីផ្សារ ១កោដិអឺរ៉ូ ។

ការប្រកួតពានរង្វាន់បាល់ទាត់ពិភពលោកនៃ អង្គការ FIFA ជាព្រឹត្តិការណ៍កីឡា ដែលទទួលការ មើលច្រើនបំផុតនៅលើពិភពលោកដូចគ្នា និងការ ប្រកួតកីឡាអូឡាំពិច ។ ដោយគិតពីសេដ្ឋកិច្ច ការ ប្រកួតមានឥទ្ធពលជាវិជ្ជមានលើកំណើននៃវិស័យ សកម្មភាពខ្លះ និងលើការអភិវឌ្ឍនៃប្រទេសរៀប ចំ ។ ហេដ្ឋារចនាសម្ព័ន្ធកីឡា មានជាអាទិ៍ពហុកីឡា ដ្ឋានត្រូវបានសាងសង់ ឬកែលំអជាថ្មី ។

ពានរង្វាន់បាល់ទាត់ពិភពលោក ក៏មានទិដ្ឋភាព នយោបាយផងដែរ ដោយនាំមកនូវតម្លៃសន្តិភាព និងភាពជាសកល ការប្រកួតក៏ជាទីលាននៃជម្លោះ ទូទៅ ។ បទឧក្រិដ្ឋជាច្រើន និងការធ្វើពហិការ មិន ចូលរួមប្រកួត បានកើតមានឡើងនៅក្នុងប្រវត្តិនៃ ការប្រកួតសម្រាប់ហេតុផលនយោបាយ ។



Photos : DR

### អង្គការ FIFA

**សហព័ន្ធអន្តរជាតិនៃសមាគមបាល់ទាត់ ឬអង្គការហ្វីហ្វា FIFA (Fédération internationale de football association) គឺជាសមាគមនៃសហព័ន្ធបាល់ទាត់ជាតិនានា ដែលបង្កើតឡើងនៅក្នុងឆ្នាំ១៩០៤ ដែលមានតួនាទីដឹកនាំ និងអភិវឌ្ឍបាល់ទាត់នៅលើពិភពលោក។ ទីស្នាក់ការរបស់សហព័ន្ធ FIFA ស្ថិតនៅទីក្រុងហ្ស៊ុយរិច (Zurich) ប្រទេសស្វីស។ អង្គការ FIFA បង្កើតដំបូងតាំងពីថ្ងៃទី ២១ ឧសភា ឆ្នាំ១៩០៤ នៅទីក្រុងប៉ារីស។ សមាជិកស្ថាបនិកដំបូងមានប្រទេស ហូឡង់ បែលហ្ស៊ិក ស៊ុយអែត ដាកណឺម៉ាក ស្វីស អេស្ប៉ាញ និងបារាំង។ មកដល់បច្ចុប្បន្ន អង្គការ FIFA បានប្រមូលផ្តុំ សហព័ន្ធបាល់ទាត់ចំនួន២០៨ ពីប្រជាជាតិនានានៅលើពិភពលោក។**

July-2010.qxd 7/6/2010 9:01 AM Page 19

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



## អ្នកនាំសារ ខែកក្កដា ដោយលោកបូជាចារ្យអ៊ិន សុន

**អាទិត្យទី ១៤ (ថ្ងៃទី០៤ ខែកក្កដា)** *( លូកា ១០.១-២।១៧-២០ )*

យើងបន្តស្តាប់ព្រះបន្ទូលដំណឹងល្អ តាមសន្ត លូកា ដែលបានចាប់ផ្តើមកាលពីថ្ងៃអាទិត្យកន្លងមក គឺព្រះយេស៊ូ បានយាងចូលទៅក្រុងយេរ៉ូសាឡឹម ។

យើងបានឃើញព្រះយេស៊ូបំពេញបេសកម្មរបស់ព្រះអង្គនៅស្រុកកាលីឡេ ។ព្រះយេស៊ូបានត្រាស់ហៅសាវ័កចំនួន ១២នាក់ ហើយបានចាត់ឱ្យពួកគេ ទៅប្រកាសដំណឹងល្អគ្រប់ទីកន្លែង ។

ចំនួននេះគឺជាសញ្ញាសំគាល់មួយពិសេស ។ វត្តមានរបស់សាវ័កបានធ្វើឱ្យ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ចាប់ផ្តើមទៅគ្រប់ទីកន្លែងក្នុងពិភពលោក ។

ការណែនាំរបស់ព្រះយេស៊ូបានធ្វើឱ្យក្រុមសាវ័កប្រតិបត្តិតាមរហូតមកដល់សព្វថ្ងៃនេះ ។ រីឯយើងទាំងអស់គ្នាវិញ តើមានឮការត្រាស់ហៅរបស់ព្រះជាម្ចាស់ឱ្យធ្វើអ្វីសម្រាប់សង្គមខ្មែរដែរឬទេ?

**អាទិត្យទី១៥ (ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១០)** *លូកា ១០.២៥-៣៧*

មានធម្មចារ្យម្នាក់មកទូលសួរព្រះយេស៊ូ សូមឱ្យព្រះអង្គពន្យល់អំពីការដែលខ្លួនត្រូវប្រព្រឹត្ត ដើម្បីឱ្យមានជីវិតអស់កល្បជានិច្ច ។ ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយតបទាំងប្រកាស អំពីធម្មវិន័យដ៏ប្រសើរបំផុតក្នុងគ្រីស្តសាសនាយើង ។ ព្រះយេស៊ូបានពន្យល់ថា យើងត្រូវតែស្រលាញ់មនុស្សគ្រប់ៗរូប ។

ចំពោះអ្នកមានជំនឿលើព្រះជាម្ចាស់មិនគ្រាន់តែធ្វើពិធី ឬធ្វើបុណ្យផ្សេងៗនោះទេ គឺត្រូវទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងជាមួយបងប្អូនដោយចិត្តស្រលាញ់ ។ ស្រលាញ់អ្នកដទៃ មានសេចក្តីថា: "ចេះលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីជួយគេហើយចេះលើកលែងទោសឱ្យ អស់អ្នកដែលបានធ្វើបាបខ្លួន" ។

ព្រះយេស៊ូបានធ្វើជាគំរូដល់យើង គឺព្រះអង្គបានជួយសង្គ្រោះមនុស្សបាប ដូចអ្នកស្រុកសាម៉ារីបានជួយអ្នករងរបួសដោយក្រុមចោរប្លន់ ។

បងប្អូនជាទីស្រលាញ់ តាមព្រះបន្ទូលដំណឹងល្អថ្ងៃនេះជួយយើងឱ្យរិះគិតថា តើនរណាជាបងប្អូនរបស់ខ្ញុំ? តើខ្ញុំស្រលាញ់ព្រះជាម្ចាស់យ៉ាងណាដើម្បីស្រលាញ់បងប្អូនបាន ?

**អាទិត្យទី១៦ (ថ្ងៃទី១៨ ខែកក្កដា ២០១០)** *លូកា ១០.៣៨-៤២*

តាមព្រះបន្ទូលដំណឹងល្អ លូកានៅថ្ងៃអាទិត្យនេះ យើងឃើញថា: "ព្រះយេស៊ូកំពុងតែធ្វើដំណើរយាងទៅក្រុងយេរ៉ូសាឡឹម ។ នៅពេលនោះស្រាប់តែមានស្ត្រីម្នាក់ឈ្មោះ ម៉ាថា ទទួលព្រះយេស៊ូក្នុងផ្ទះរបស់នាង ។ នាងម៉ាថាដែលត្រូវជាបងស្រី ម៉ារី និងឡាសា បានខិតខំរៀបចំម្ហូបអាហារជាច្រើនដើម្បីទទួលព្រះយេស៊ូ និងក្រុមសាវ័កទាំង១២នាក់ ។ ចំពោះនាងម៉ារីវិញ នាងបានអង្គុយនៅជាមួយព្រះយេស៊ូដើម្បីស្តាប់ព្រះបន្ទូលព្រះអង្គ ។ យើងឃើញថា: នាងម៉ាថា និងនាងម៉ារី មានការរវល់ដូចគ្នា តែព្រះយេស៊ូបានប្រាប់ទៅនាងម៉ាថា ថា ទុកឱ្យនាងម៉ារីអង្គុយស្តាប់ ព្រះអង្គ ពីព្រោះជាការចាំបាច់បំផុត ។

រីឯយើងជាគ្រីស្តបរិស័ទ យើងត្រូវតែយកចិត្តទុកដាក់នូវការស្តាប់ព្រះបន្ទូលព្រះយេស៊ូ ហើយត្រូវយកចិត្តទុកដាក់យកអាសាអ្នកដទៃ ដូចជាអ្នកក្រីក្រជាដើម ។

**អាទិត្យទី១៧ (ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០)**

ក្នុងអត្ថបទគម្ពីរ ដំណឹងល្អថ្ងៃនេះ លោកលូកា បានលើកយកការប្រៀនប្រដៅផ្សេងៗរបស់ព្រះយេស៊ូអំពីពាក្យអធិដ្ឋាន "ឱព្រះបិតា" ។ ព្រះយេស៊ូបង្រៀនយើងឱ្យព្យាយាមអង្វរទៅព្រះបិតា ព្រោះយើងត្រូវការឱ្យព្រះអង្គជួយយើងជានិច្ច ។

ចំពោះ យើងជាគ្រីស្តបរិសទ័ រាល់ពេលដែលយើងអធិដ្ឋានធម៌ ឱព្រះបិតា គឺនាំឱ្យយើងឃើញសេចក្តីស្រលាញ់ និងព្រះហឫទ័យល្អយ៉ាងខ្លាំងដែលព្រះជាម្ចាស់មានចំពោះមនុស្សលោក ។

ការអង្វរសូមឱ្យព្រះជាម្ចាស់គង់នៅជាមួយយើង

ការអង្វរសូមឱ្យព្រះជាម្ចាស់ប្រទានអាហារឱ្យយើងប្រចាំថ្ងៃ

យើងអង្វរសូមឱ្យព្រះជាម្ចាស់លើកលែងទោសឱ្យ ។ ដូច្នេះយើងក៏ត្រូវចេះលើកលែងទោសឱ្យអ្នកដទៃដែរ ។ យើងត្រូវចេះឱ្យសេចក្តីស្រលាញ់ និងធម៌មេត្តាដល់បងប្អូន អ្នកដទៃដូចព្រះបិតានៃស្ថានបរមសុខប្រទានឱ្យមកយើងម្នាក់ៗដែរ ។

សូមបងប្អូន កុំភ្លេចសូត្រធម៌ ឱព្រះបិតា មុនពេលចាប់ផ្តើមធ្វើការងារ និងមុនពេលចូលគេង ។

## ព័ត៌មាន

### កិច្ចប្រជុំគណៈកម្មការមហាសន្និបាតទូទាំងប្រទេស

មហាសន្និបាតនៅទូទាំងប្រទេសដែលព្រះសហគមន៍កាតូលិក តែងតែប្រារព្ធឡើង ៣ ឆ្នាំម្តង បានជិតឈានមកដល់ហើយ ដោយនឹងធ្វើឡើងនៅខែសីហាខាងមុខនេះ ។

ហេតុដូចនេះទើបកាលពីថ្ងៃទីទី១៨ ខែមិថុនា ឆ្នាំ២០១០ នៅឯផ្ទះភូមិភាគសម្តេចប៉ាប ប៉េណេឌីតូ ទី១៦ នៅរាជធានី ភ្នំពេញ យុវជនយុវនារីដែលតំណាងឱ្យភូមិភាគទាំង ៣ គឺភូមិភាគកំពង់ចាម ភូមិភាគបាត់ដំបង និងភូមិភាគភ្នំពេញ ព្រមទាំងមានការចូលរួមពីលោកបូជាចារ្យ ក៏ដូចជាបងស្រីបានធ្វើការរៀបចំនូវកិច្ចប្រជុំជាលើកដំបូងសម្រាប់ការរៀបចំមហាសន្និបាតនេះ ។

មហាសន្និបាតដែលនឹងធ្វើឡើងនៅថ្ងៃទី២៣-២៧ខែសីហា ឆ្នាំ២០១០ នឹងត្រូវរៀបចំឡើងនៅក្រោមប្រធានបទ : "ខ្ញុំជាសាក្សីរបស់ព្រះយេស៊ូគ្រីស្តក្នុងសង្គម!" ។

យុវជនយុវនារីសរុបទាំងអស់ដែលចូលរួមក្នុងកម្មវិធីនេះមានចំនួន៣០០នាក់ ដែលមកពីភូមិភាគទាំងបីនៃព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា ហើយដោយភូមិភាគនីមួយៗ អាចមានយុវជនចូលរួមចំនួន ១០០ នាក់ ។ យុវជនយុវនារី ដែលអាចចូលរួមត្រូវតែមានអាយុចាប់ពី១៧ឆ្នាំឡើងទៅ ហើយយ៉ាងតិចណាស់ ក៏ត្រូវទទួលជំហានទីមួយ ឬមានសកម្មភាពច្រើននៅក្នុងព្រះសហគមន៍កាតូលិក ។

ការប្រជុំលើកជាទី២ សម្រាប់ការរៀបចំមហាសន្និបាតទូទាំងប្រទេស នឹងត្រូវធ្វើនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ ខាងមុខ ។

**នូ អច្ឆរិចិត្រា**



Photo : DR

## “ជៀសពីគ្រឿងញៀន ដើម្បីការពារជីវិតអ្នក”

# លេខទូរស័ព្ទដែលត្រូវហៅ បន្ទាន់

*ករណីសង្ស័យគ្រុនផ្តាសាយថ្មី A/H1N1 :

១១៥ / ០១២ ៤៨៨ ៩៨១ / ០៨៩ ៦៦៩ ៥៦៧។

*មណ្ឌលកែប្រែអ្នកញៀនគ្រឿងញៀន :

០១២ ៨១២ ១១៧ / ០១៥ ៨៩៣ ៩៩៩។

*រថយន្តសង្គ្រោះបន្ទាន់ :

-ភ្នំពេញ ០២៣ ៧២៤ ៨៩១។ -សៀមរាប ០៦៣ ៧៦១ ១១៩។

## ល្បែងកំសាន្ត

**រកផ្លូវ**

សូមប្រិយមិត្តជួយស្វែងរកផ្លូវឱ្យអណ្តើកទៅកាន់កោះសុខសាន្តនេះផង។



Photo : jeux-loisirs-enfants

## ការងារប្រចាំខែ

- ថ្ងៃទី៣-០៤ កក្កដា ២០១០ : សិក្ខាសាលារបស់យុវជន យុវនារី ក្រោមប្រធានបទ “ព្រះវិញ្ញាណកំពុងដឹកនាំជីវិតយើង” រៀបចំធ្វើឡើងនៅព្រះសហគមន៍តាកែវ ដែលមានយុវជនចូលរួមប្រហែល ១២០នាក់។
- ថ្ងៃទី០៤ កក្កដា ២០១០ : ពិធីសម្ពោធកន្លែងដាក់ជួងថ្មីនៅព្រះសហគមន៍អរិយក្សត្រ ភូមិភាគភ្នំពេញ។
- ថ្ងៃ០៤-១១ កក្កដា ២០១០ : ការហាត់រាំរបាំប្រពៃណីខ្មែរសម្រាប់ក្រុមយុវជនភូមិភាគកំពង់ចាម នៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃទី០៧ កក្កដា ២០១០ : ពិធីសម្ពោធមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដុនបូស្កូទួលគោកផ្នែកនារី រៀបចំឡើងនៅសាលាបច្ចេកទេសដុនបូស្កូទួលគោក។
- ថ្ងៃទី០៩ កក្កដា ២០១០ : កិច្ចប្រជុំលើកទី២ លើគម្រោងការសន្និបាតយុវជនយុវនារីសម្រាប់ឆ្នាំ២០១០។
- ថ្ងៃទី១៨ កក្កដា ២០១០ : ពិធីសម្ពោធព្រះវិហារថ្មីមានឈ្មោះព្រះសហគមន៍កាតូលិកសំរោងធំ ភូមិភាគកំពង់ចាម។
- ថ្ងៃទី៣០ កក្កដា ២០១០ : ពិធីបិទឆ្នាំសិក្សា២០០៩-២០១០ របស់សាលាមត្តេយ្យសន្តិ លូស៊ី នៅព្រះសហគមន៍កាតូលិកព្រះកុមារយេស៊ូបឹងទំពុន។
- ថ្ងៃទី៣១ កក្កដា ២០១០ : សិក្ខាសាលាយុវជនយុវនារី លើកទី២ ក្រោមប្រធានបទ “ព្រះវិញ្ញាណកំពុងដឹកនាំជីវិតយើង” នៅព្រះសហគមន៍កាតូលិកកំពត។
- ចាប់ពីខែកក្កដា រហូតដល់ខែកញ្ញា ឆ្នាំ២០១០រៀងរាល់ថ្ងៃសុក្រ និងថ្ងៃសៅរ៍ : នៅព្រះសហគមន៍កាតូលិកព្រះកុមារយេស៊ូបឹងទំពន់ មានការផ្លាស់ប្តូរពេលវេលានៃការថ្វាយអភិបូជា ដោយប្តូរពីម៉ោង ៦ល្ងាច ទៅម៉ោង ៦:៣០នាទី ល្ងាចវិញ។

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក CSC បានផលិត CD Vol.11 ចម្រៀងសម្រាប់អធិដ្ឋាន CD Vol នេះមាន ចម្រៀងចំនួន ១២បទ សម្រាប់ការអធិដ្ឋានរបស់គ្រីស្តបរិស័ទ តម្លៃត្រឹម ៨000រៀល។
ទូរស័ព្ទទំនាក់ទំនង : ០១៧ ៣០៥ ២៦០,
០៩៩ ៩៩៩ ៨៦៤,
០២៣ ២២៤ ១២០។